សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការផ្តល់អត្ថប្រយោជន៍ជូនដល់កម្មករ និយោជិតក្រៅប្រព័ន្ធ

# (ក្នុង និងក្រៅក្របខ័ណ្ឌ ប.ស.ស)

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


ចាត់តែងឡើងដោយ

និស្សិតឈ្មោះ៖ **ស្ងួន ផេងអាន**

**ញឹង ពិនិត្យ**

សាស្ត្រាចារ្យណែនាំ

លោក **ម៉ៅ បុណ្ណា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **សួន ផេង អាន** និង **ញ៉ឹង ពិនិត្យ** ជានិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី១៨ ឆ្នាំសិក្សា ២០១៧-២០១៨ ក្រុម L4C4 នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

| | | | |
|---|---|---|---|
| លោកឪពុក ឈ្មោះ | **សួន ទ្រៀត** | លោកឪពុក ឈ្មោះ | **ស៊ន ញ៉ឹង** |
| និង អ្នកម្តាយឈ្មោះ | **ងួន ចិន្តា** | និង អ្នកម្តាយ ឈ្មោះ | **ស្រេង ចាន់ធឿន** |

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ចំពោះកិច្ចខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ ថែរក្សាកូនយ៉ាងលំបាកលំបិន ប្រកបដោយព្រហ្មវិហារធម៌ទាំង៤ គឺមេត្តា ករុណា មុទិតា និងឧបេក្ខា។

សូមថ្លែងអំណរគុណជាអនេកប្បការ ចំពោះលោកសាស្ត្រាចារ្យ **ម៉ៅ បុណ្ណា** ដែលលោកគ្រូបានលះបង់ពេលវេលាដ៏មានតម្លៃខិតខំជួយជ្រោមជ្រែងអស់ពីកម្លាំងកាយចិត្ត ក្នុងការណែនាំ និងជួយកែតម្រូវរាល់ការសរសេររបស់យើងខ្ញុំតាំងពីពេលចាប់ផ្តើមរហូតដល់បញ្ចប់ជាស្ថាពរ។

ជាមួយគ្នានេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកសាស្ត្រាចារ្យ **ជួន ប៊ុនធី** ដែលលោកគ្រូតែងតែផ្តល់ភាពងាយស្រួលដល់យើងខ្ញុំ ក្នុងការសាកសួរពីរបៀបរបបនៃការសរសេរសារណាឱ្យមានលក្ខណៈត្រឹមត្រូវ តាមតម្រង់បែបបទសាកលវិទ្យាល័យបានកំណត់។

ហើយក៏សូមថ្លែងអំណរគុណចំពោះលោក **សុខ បូរ៉ា** ប្រធានការិយាល័យតារាកាលិក និងលោកស្រី **ស៊ឹម ស៊ុនណារី** អនុប្រធានការិយាល័យបញ្ជិកា និងភាគទាននៃបេឡាជាតិរបបសន្តិសុខសង្គម ដែលបានអនុញ្ញាតផ្តល់កិច្ចសម្ភាសន៍ និងឯកសារពាក់ព័ន្ធនឹងប្រធានបទសារណានេះដល់យើងខ្ញុំទាំងពីរនាក់ផងដែរ។

សូមថ្លែងអំណរគុណ ចំពោះលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ដែលបានបង្ហាត់បង្រៀនកន្លងមក និងមិត្តនិស្សិតទាំងអស់ ដែលបានខិតខំស្វះស្វែងជួយរក និងផ្តល់ឱ្យពួកខ្ញុំនូវឯកសារដែលពាក់ព័ន្ធទាំងឡាយ។ ទាំងអស់នេះហើយ ដែលជាចលករស្មារតី និងសម្ភារៈដ៏ខ្លាំងក្លា សម្រាប់ការជំរុញល្បឿននៃការសរសេររបស់យើងខ្ញុំ ឱ្យមានភាពរលូនទៅមុខជានិច្ច។

នាទីបញ្ចប់នេះ យើងខ្ញុំសូមធ្វើការបួងសួងដល់ វត្ថុស័ក្តិសិទ្ធិទាំងអស់នៅក្នុងលោកតាមថែរក្សា អ្នកមានគុណទាំងទ្វេ ទទួលបានសេចក្តីសុខ និងសុខភាពមាំមួន អាយុយឺនយូរ ព្រមទាំងជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមជានិស្សិត យើងម្នាក់ៗ គឺពិតជាមានតួនាទីយ៉ាងសំខាន់ ជាជំនួយដល់ការអភិវឌ្ឍសង្គមជាតិយើង។ ឈរលើវត្ថុបំណងដ៏ពិសេសនេះ ក្រុមស្រាវជ្រាវយើងខ្ញុំ ដែលជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរួបរួមសាមគ្គីគ្នា ក្នុងការរៀបចំចងក្រងសារណាមួយនេះឡើង ដែលផ្តោតការឈ្វេងយល់លើប្រធានបទមួយដែលមានចំណងជើងថា «**ការផ្តល់អត្ថប្រយោជន៍ជូនដល់កម្មករនិយោជិតក្រៅប្រព័ន្ធ**» ក្នុងគោលបំណងជួយដល់ការសិក្សានៃមិត្តសិស្សនិស្សិត ប្រជាពលរដ្ឋ និងជាពិសេសចំពោះកម្មករនិយោជិតក្រៅប្រព័ន្ធ ក៏ដូចជាអ្នកពាក់ព័ន្ធគ្រប់រូបជុំវិញបញ្ហាផ្សេងៗ ទាក់ទងនឹងផលប្រយោជន៍ដែលបុគ្គលម្នាក់ៗត្រូវទទួលបានពីមូលនិធិសមធម៌សុខាភិបាល តាមរយៈការចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គមនេះ។

ប្រត្យក្សណាស់ ប្រជាពលរដ្ឋគ្រប់រូបគួរតែយល់ដឹងឱ្យបានច្បាស់ ពីទិដ្ឋភាពក្នុងសង្គមដែលពួកគាត់កំពុងរស់នៅ រួមទាំងផលប្រយោជន៍ផ្សេងៗដែលបុគ្គលម្នាក់ៗត្រូវទទួលបាន។ ដើម្បីឆ្លើយតបនឹងតម្រូវការខាងលើ ទើបក្រុមយើងខ្ញុំបានខិតខំធ្វើការបកស្រាយយ៉ាងច្បាស់លាស់ទាក់ទងនឹងការផ្តល់ជូននូវអត្ថប្រយោជន៍ដែលកម្មករនិយោជិតទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធអាចមានសិទ្ធិទាមទារ និងទទួលបានពីផលប្រយោជន៍អស់នោះ។

យើងខ្ញុំមានសេចក្តីសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា សារណាមួយក្បាលនេះ នឹងរួមចំណែកផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងផ្តល់ពុទ្ធិដល់អ្នកសិក្សាទាំងឡាយ ក៏ដូចជាការចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាឱ្យមានភាពរីកចម្រើនផងដែរ។ ជាទីបញ្ចប់យើងខ្ញុំសូមធ្វើការអភ័យទោស រាល់កំហុសឆ្គង និងចំណុចខ្វះខាតទាំងឡាយដែលកើតមានដោយអចេតនា ហើយយើងខ្ញុំក៏សូមទទួលស្វាគមន៍រាល់មតិរិះគន់ស្ថាបនាផ្សេងៗដើម្បីធ្វើការកែលម្អឱ្យប្រសើរឡើង និងបន្ថែមគំនិតថ្មីៗជាច្រើនទៀត សម្រាប់ទុកជាស្នាដៃដល់និស្សិតជំនាន់ក្រោយៗ ។

## មាតិកា

*ទំព័រ*

សេចក្ដីផ្ដើម ..... ០១

ជំពូកទី១៖ ទិដ្ឋភាពទូទៅនៃបេឡាជាតិរបបសន្តិសុខសង្គម ..... ០៤

១.១.គោលបំណង ..... ០៥

១.២. ភារកិច្ច ..... ០៥

១.៣. ប្រភពធនធាន ..... ០៦

១.៤ កម្មករនិយោជិតក្នុងប្រព័ន្ធ ..... ០៧

១.៤.១. គាងការលិកហានិភ័យការងារ ..... ០៨

១.៤.២. គាងការលិកថែទាំសុខភាព ..... ០៩

១.៥ កម្មករនិយោជិតក្រៅប្រព័ន្ធ ..... ០៩

ជំពូកទី២៖ ការចុះបញ្ជិកាកម្មករនិយោជិកក្រៅប្រព័ន្ធ ..... ១១

២.១. បញ្ជិកាសហគ្រាស គ្រឹះស្ថាន អង្គការ សមាគមនៃការងារក្រៅប្រព័ន្ធ សាលាក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ..... ១២

២.២. បញ្ជិកាកម្មករនិយោជិតក្រៅប្រព័ន្ធ ..... ១៣

២.៣. បញ្ជិកាសមាជិកនៃអង្គការ សមាគមនានានៃការងារក្រៅប្រព័ន្ធ ..... ១៤

២.៤. បញ្ជិកាសមាជិកភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ..... ១៤

២.៥. បញ្ជិកាកីឡាករ និងកីឡាការិនីអាជីព ..... ១៥

២.៦. ប័ណ្ណមូលនិធិសមធម៌សុខាភិបាលក្នុងក្របខ័ណ្ឌ បេឡាជាតិរបបសន្តិសុខសង្គម ..... ១៩

ជំពូកទី៣៖ អត្ថប្រយោជន៍នៃប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល ..... ២៣

៣.១. មូលដ្ឋានសុខាភិបាល ..... ២៣

៣.២. តារាងកាលិកថែទាំសុខភាព និងប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូន ២៤
៣.២.១. តារាងកាលិកថែទាំសុខភាពនៃកម្មករនិយោជិតក្រៅប្រព័ន្ធ ២៤
៣.២.២. ប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូន ២៥
៣.៣. សិទ្ធិទាមទាររបស់កម្មករនិយោជិតក្រៅប្រព័ន្ធក្នុងក្របខ័ណ្ឌ
បេឡាជាតិរបបសន្តិសុខសង្គម ២៧
សេចក្តីសន្និដ្ឋាន ២៩
អនុសាសន៍ ៣១
ឯកសារយោង
តារាងឧបសម្ព័ន្ធ
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលបានញាំញីទៅដោយសង្គ្រាម និងវិបត្តិនយោបាយអស់រយៈពេលច្រើនទសវត្សមកហើយ រហូតមកដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ទើបបានយើងឃើញមាន**កិច្ចព្រមព្រៀងសន្តិភាពនាទីក្រុងប៉ារីស**កើតឡើង ជាហេតុនាំមកនូវសន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់ជូនជាតិជាបន្តបន្ទាប់រៀងៗមក ហើយឈានទៅដល់សមាហរណកម្មនាឆ្នាំ១៩៩៨ តាមរយៈ**គោលនយោបាយឈ្នះ ឈ្នះ** ក្រោមមាគ៌ាដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានធ្វើឱ្យប្រទេសដ៏កម្សត់មួយនេះ ស្គាល់សុខសន្តិភាពពេញលេញតែម្តង។

ទើបជានិច្ចកាល អាទិភាពគោលនយោបាយចម្បងនៃរាជរដ្ឋាភិបាល គឺការរក្សាសន្តិភាព ស្ថិរភាព នយោបាយ និងសន្តិសុខជាតិដែលជាបុរេលក្ខណដ៏ចាំបាច់ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ចដែលនឹងអនុញ្ញាតឱ្យកម្ពុជាងើបមុខឡើងវិញ ហើយចាប់ផ្តើមអភិវឌ្ឍន៍សារជាថ្មីម្តងទៀតពីស្ថានភាពខ្ទេចខ្ទាំគ្រប់វិស័យក្រោមរបបប្រល័យពូជសាសន៍នាឆ្នាំ១៩៧៥ដល់១៩៧៩។ ទន្ទឹមនេះ ចាប់តាំងពីដំណាក់កាលដំបូងនៃការស្តារសេដ្ឋកិច្ចជាតិ ក្នុងគោលបំណងកសាងធនធានមនុស្ស និងលើកកម្ពស់ភាពថ្លៃថ្នូររបស់ប្រជាជនឡើងវិញ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្ពស់ទៅលើសកម្មភាពគាំពារសង្គមនានា។

ប្រទេសជាតិមានការរីកចម្រើនជាលំដាប់ ក្នុងពេលបោះជំហានលើមាគ៌ានៃការកសាង និងការអភិវឌ្ឍលើគ្រប់វិស័យ។ ប្រជាជនកម្ពុជាគ្រប់រូបបាននិងកំពុងទទួលផ្លែផ្កាពីសេចក្តីសុខសន្តិភាព ស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ក្នុងអត្រាមធ្យមប្រមាណ៧.៧(ប្រាំពីរក្បៀសប្រាំពីរ)ភាគរយ នាអំឡុង២(ពីរ)ទស្សវត្សកន្លងមកនេះ។ សមិទ្ធផលនាពេលបច្ចុប្បន្ននេះ គឺជាការបោះជំហានឆ្ពោះទៅរកការសម្រេចបានគោលដៅនៃការពន្លឿនកំណើនសេដ្ឋកិច្ច ការបង្កើតឱកាសការងារជាអតិបរិមា និងការកសាងសង្គមមួយប្រកបដោយសមធម៌។ រាជរដ្ឋាភិបាលបានខិតខំដាក់ឱ្យដំណើរការ និងទ្រទ្រង់គោលនយោបាយសង្គមកិច្ចជាច្រើន។

តាមរយៈនេះ ប្រជាជនកម្ពុជា និងជាពិសេសបងប្អូននៃការងារវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងបងប្អូនកម្មកនិយោជិតដែលបម្រើការងារតាមសហគ្រាស គ្រឹះស្ថានទទួលបានការគាំពារក្រោមទម្រង់រូបភាពផ្សេងៗក្នុងក្របខ័ណ្ឌនៃការងារគាំពារសង្គមដូចជា ការបង្កើតឱ្យមានបេឡាជាតិរបបសន្តិសុខសង្គម មូលនិធិសមធម៌សុខាភិបាល ដើម្បីផ្តល់ការធានាសន្តិសុខប្រាក់ចំណូលសម្រាប់ប្រជាជនតាមមុខសញ្ញាពាក់ព័ន្ធនានា មានជាអាទិ៍ការផ្តល់តាវកាលិកហានិភ័យការងារ តាវកាលិក

ថែទាំសុខភាព ការពិនិត្យ សម្រាកព្យាបាលឥតបង់ថ្លៃសេវាតាមមូលដ្ឋានសុខាភិបាលសាធារណៈ និងការផ្តល់ជូនប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូន ចំពោះកម្មករនិយោជិតជានារីទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ[១]។

## ក. គោលបំណង

ដើម្បីសិក្សាឈ្វេងយល់បន្ថែមអំពីយន្តការនៃប្រព័ន្ធគាំពារសង្គម ដែលរាជរដ្ឋាភិបាលកំពុងបន្តអនុវត្ត តាមរយៈបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់ការផ្តល់ជូននូវអត្ថប្រយោជន៍ទៅដល់បណ្តាកម្មករ កម្មការិនី ពិសេសការយកចិត្តទុកដាក់ និងការគិតគូរចំពោះកម្មករនិយោជិតនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលមានចំនួនកើនឡើងគួរឱ្យកត់សម្គាល់ ឈរលើគោលការណ៍សមធម៌ក្នុងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម។ ការបង្ហាញពីស្ថាប័ន អង្គភាពទទួលភារៈសម្របសម្រួល និតិវិធីនៃការកំណត់អត្តសញ្ញាណ ដើម្បីធ្វើការចុះបញ្ជិកាអ្នកដែលគួរទទួលបាននូវអត្ថប្រយោជន៍ឱ្យសមស្រប និងងាយស្រួលក្នុងការគ្រប់គ្រងទិន្នន័យពួកគាត់ និងអត្ថប្រយោជន៍ពីមូលនិធិសមធម៌សុខាភិបាលដែលត្រូវផ្តល់ដល់កម្មករនិយោជិតនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

## ខ. ដែនកំណត់ និងវិសាលភាព

សារណានេះ ផ្តោតលើការសរសេរស្រាវជ្រាវអំពីលក្ខខណ្ឌគតិយុត្ត និងគោលបំណងនៃការបង្កើតស្ថាប័ន អង្គភាព ដើម្បីអនុវត្តយន្តការក្នុងការជួយសម្រាលបន្ទុក ក៏ដូចជាការលើកម្ពស់កម្រិតជីវភាពបងប្អូននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ស្ថិតក្នុងបរិបទនៃក្របខ័ណ្ឌប្រព័ន្ធសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គមរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីកុំឱ្យសារណានេះ មានទំហំហួសកំណត់យើងសូមមិនលើកយកការរៀបចំ និងលក្ខន្តិកៈនៃការចូលជាសមាជិករបស់អង្គការ សមាគមនានានៃការងារក្រៅប្រព័ន្ធ ក៏ដូចជាសមាជិកភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ កីឡាករ និងកីឡាការិនីអាជីពនោះទេ ហើយក៏មិនបានសិក្សា បង្ហាញពីការផ្តល់សេវា និងប្រភេទសេវាថែទាំសុខភាពតាមមូលដ្ឋានសុខាភិបាលសាធារណៈឱ្យលម្អិតស៊ីជម្រៅផងនោះដែរ។ អ្វីដែលផ្តោតសំខាន់ក្នុងសារណានេះ គឺការចុះទៅសិក្សាស្រាវជ្រាវដោយផ្ទាល់ត្រឹមកម្រិតបេឡាជាតិរបបសន្តិសុខសង្គមតែប៉ុណ្ណោះ។

## គ. វិធីសាស្ត្រនៃការសរសេរសារណា

[១] ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧

ការសរសេររៀបចំឱ្យលេចចេញនូវរូបរាងសារណានេះ គឺពឹងផ្អែកលើប្រភពទិន្នន័យដែលបោះពុម្ពផ្សាយនៅតាមបណ្ណាល័យ អ៊ិនធឺណេត និងឯកសារមួយចំនួនទៀតដូចជា ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីណែនាំ ឯកសារគោលនយោបាយជាតិ និងឯកសារពាក់ព័ន្ធនានា។ លើសពីនេះទៅទៀត គឺជាលទ្ធផលនៃការចុះទៅសិក្សាស្រាវជ្រាវ សង្កេតជាក់ស្តែង និងកិច្ចសម្ភាសន៍ផ្ទាល់ជាមួយមន្ត្រីពាក់ព័ន្ធ នៅតាមការិយាល័យជំនាញនីមួយៗ នៃបេឡាជាតិរបបសន្តិសុខសង្គម។

**ឃ. រចនាសម្ព័ន្ធ**

សារណានេះនឹងចាប់ផ្តើមពី សេចក្តីផ្តើមៈ បង្ហាញពីលំនាំទូទៅ គោលបំណង ដែនកំណត់ និងវិសាលភាព វិធីសាស្ត្រប្រមូលព័ត៌មាន និងរចនាសម្ព័ន្ធនៃបទបង្ហាញរបស់សារណា ដោយចែកជា៣(បី)ជំពូក ជំពូកទី១ៈ ទិដ្ឋភាពទូទៅនៃបេឡាជាតិរបបសន្តិសុខសង្គម បង្ហាញពីទិដ្ឋភាពរួមនៃការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមក្នុងក្របខ័ណ្ឌកម្ពុជា ជំពូកទី២ៈ ការចុះបញ្ជិកាកម្មករនិយោជិកក្រៅប្រព័ន្ធ ផ្តោតលើនីតិវិធីនៃការចុះបញ្ជី និងចេញប័ណ្ណមូលនិធិសមធម៌ជូនដល់ពលករកម្មករនិយោជិតនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ទីកន្លែងដែលពួកគាត់អាចធ្វើប័ណ្ណមូលនិធិសមធម៌ និងទំនាក់ទំនងសួរនាំព័ត៌មានពេលជួបបញ្ហាផ្សេងៗ និងជំពូកទី៣ៈ អត្ថប្រយោជន៍នៃប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និយាយអំពីតាវកាលិកថែទាំសុខភាព តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល។ ចុងបញ្ចប់ គឺសេចក្តីសន្និដ្ឋាន ដែលជាការសន្និដ្ឋានបញ្ចប់នៃការសេសេរសារណា និងអនុសាសន៍ ការជូនជាគំនិតយោបល់ យល់ឃើញក្រោយសិក្សាលើប្រធានបទ។

## ជំពូកទី១៖ ទិដ្ឋភាពទូទៅនៃបេឡាជាតិរបបសន្តិសុខសង្គម

រាជរដ្ឋាភិបាលកម្ពុជាដោយផ្អែកលើភាពចាំបាច់ចំពោះមុខក៏បានបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានបេសកកម្មបម្រើសេវាសាធារណៈមានលក្ខណៈសង្គម មានឈ្មោះថា **បេឡាជាតិរបបសន្តិសុខសង្គម** ដែលសរសេរជាអក្សរកាត់ថា **ប.ស.ស**[២] លេចចេញជារូបរាងឡើងតាមរយៈអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម ។

ស្ថាប័នមួយនេះស្ថិតនៅក្រោមអាណាព្យាបាលផ្នែកបច្ចេកទេស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតនៅក្រោមអាណាព្យាបាលផ្នែកហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមានស្វ័យភាពខាងផ្នែកហិរញ្ញវត្ថុ។ ដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលមានអំណាចដើម្បីគ្រប់គ្រងគ្រឹះស្ថាននេះ មានបេសកកម្មក្នុងការតម្រង់ទិស និងត្រួតពិនិត្យដំណើរការប្រព្រឹត្តទៅនៃបេឡាជាតិរបបសន្តិសុខសង្គម ដោយមានសមាសភាព៩(ប្រាំបួន)រូប គឺជាតំណាងរាជរដ្ឋាភិបាល៥(ប្រាំ)រូប តំណាងនិយោជក២(ពីរ)រូប និងតំណាងកម្មករនិយោជិត២(ពីរ)រូប។ ក្នុងនោះដែរ តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ១(មួយ)រូបជាប្រធាន តំណាងទីស្តីការគណៈរដ្ឋមន្ត្រី១(មួយ)រូបជាសមាជិក តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ១(មួយ)រូបជាសមាជិក តំណាងក្រសួងសុខាភិបាល១(មួយ)រូបជាសមាជិក តំណាងនិយោជក២(ពីរ)រូបជាសមាជិក និងតំណាងកម្មករនិយោជិត២(ពីរ)រូបជាសមាជិក និងនាយក ប.ស.ស ជាសមាជិកស្វ័យប្រវត្តិ[៣]។

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលបេឡាជាតិរបបសន្តិសុខសង្គម គឺត្រូវបានតែងតាំងដោយអនុក្រឹតសម្រាប់អាណត្តិ៣(បី)ឆ្នាំ រៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមសំណើរបស់ក្រសួង ស្ថាប័ន ឬអង្គការវិជ្ជាជីវៈដែលសមាជិកនោះតំណាងឱ្យ ហើយត្រូវមានសមត្ថភាពខាងវិស័យសង្គមកិច្ច សេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ[៤]។

---

[២] មាត្រា១ នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[៣] មាត្រា៤ នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[៤] មាត្រា៦ នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

នាយកនៃ ប.ស.ស ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រី នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានភារកិច្ចចាត់ចែងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ ប.ស.ស ហើយទទួលបានអំណាចចាំបាច់សម្រាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពពេញលេញក្នុងការដឹកនាំគ្រឹះស្ថានស្របតាមច្បាប់ និងជាតំណាងនៃ ប.ស.ស ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់[៥]។

## ១.១.គោលបំណង

បេឡាជាតិរបបសន្តិសុខសង្គមនេះបង្កើតឡើង ក្នុងគោលដៅដើម្បីជាយន្តការសម្រាប់ការអនុវត្តរបបសន្តិសុខសង្គមដោយឈរលើគោលបំណង ការពារចំពោះប្រជាពលរដ្ឋ ដែលមិនមានលទ្ធភាពរកប្រាក់ចំណូល ឬកំពុងប្រឈមនឹងការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ ដោយសារហានិភ័យសង្គម តាមរយៈការផ្តល់នូវធនធានខាងហិរញ្ញវត្ថុ ឬវត្ថុប្រើប្រាស់ចាំបាច់ ឬក៏ការផ្តល់សេវាកម្មផ្សេងៗ ធានាសមាជិកសង្គមមិនឱ្យធ្លាក់ទៅក្នុងហានិភ័យនៃការបាត់បង់ប្រាក់ចំណូល និងធ្លាក់ទៅក្នុងភាពក្រីក្រ។ ការផ្តល់ជូនការគាំពារចំពោះប្រជាពលរដ្ឋផ្អែកលើទស្សនទាននៃការចែករំលែក និងគោលការណ៍សាមគ្គីធម៌ក្នុងសង្គមធានាបាននូវសន្តិសុខប្រាក់ចំណូល។

តាមរយៈរបបនេះ សមាជិកសង្គមត្រូវបានគាំពារមិនឱ្យធ្លាក់ទៅក្នុងហានិភ័យ នៃការបាត់បង់ប្រាក់ចំណូល ដោយសារហានិភ័យសង្គមជាយថាហេតុណាមួយឡើយ។ ការណ៍នេះហើយញ៉ាំងពួកគាត់ឱ្យមានជំនឿទុកចិត្តមកលើសង្គមទាំងមូល ដែលជាបច្ច័យនាំទៅដល់ភាពនឹងនរ ធានាស្ថិរភាព ភាពសុខដុមរមនាក្នុងសង្គម និងរួមចំណែកជួយពន្លឿនការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល[៦]។

## ១.២. ភារកិច្ច

ក្រោយការបង្កើតឡើងបេឡាជាតិរបបសន្តិសុខមានមុខងារភារកិច្ចអនុវត្តដូចខាងក្រោម៖

១- គ្រប់គ្រងរបបសន្តិសុខសង្គមដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

[៥] មាត្រា១១ និង១២ នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[៦] http://www.nssf.gov.kh/default

២- ធានាផ្តល់ភាពសមស្របនូវតាវកាលិកទាំងឡាយសម្រាប់សមាជិកនៃ ប.ស.ស ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេល ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ មាតុភាព ជាដើម

៣- ប្រមូលភាគទានពីសមាជិកនៃ ប.ស.ស និងនិយោជក

៤- សម្របសម្រួល និងរៀបចំឱ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួន

៥- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីៈ

ក‗ អប់រំផ្សព្វផ្សាយអំពីរបៀបបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ

ខ‗ ចាត់វិធានការផ្នែកបច្ចេកទេសសន្តិសុខ និងអនាម័យការងារ

៦- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវ និងអង្កេតហានិភ័យការងារ

៧- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម[៧]។

កន្លងនាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចមួយបន្ថែមទៀត សម្រាប់បេឡាជាតិរបបសន្តិសុខសង្គម គឺការចុះបញ្ជិកាកម្មករនិយោជិតក្រៅប្រព័ន្ធ សមាជិកនៃអង្គការ សមាគមនានានៃការងារក្រៅប្រព័ន្ធ សមាជិកភូមិនិងក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ដូចជាកីឡាករ កីឡាការិនីអាជីព ដើម្បីធ្វើយ៉ាងណាអនុញ្ញាតឱ្យពួកគាត់ទទួលបានអត្ថប្រយោជន៍ ពីមូលនិធិសមធម៌សុខាភិបាលដែលជាការផ្តល់ជូនដោយរាជរដ្ឋាភិបាល[៨]។

### ១.៣. ប្រភពធនធាន

គ្រប់កិច្ចដំណើរការរបស់ស្ថាប័ន ឬអង្គភាពមួយប្រព្រឹត្តទៅបានជាការចាំបាច់ណាស់តម្រូវឱ្យមានការចូលរួមចំណែកពីកត្តាជាច្រើនយ៉ាង សម្រាប់បេឡាជាតិរបបសន្តិសុខសង្គមអាចដំណើរការមកបានក៏ដោយមានប្រភពធនធានជាចាំបាច់ដូចខាងក្រោមៈ

១ - ការឧបត្ថម្ភធនដំបូងពីរដ្ឋសម្រាប់ការបង្កើត

២ - ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈ ដែលមានចែងក្នុងថវិការដ្ឋដូចជាឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន

[៧] មាត្រា៣ នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[៨] http://www.nssf.gov.kh/default

៣ - ការបង់ភាគទានរបស់សមាជិកនៃប.ស.ស និងនិយោជក ដែលទុកសម្រាប់ហិរញ្ញប្បទានលើផ្នែកនីមួយៗ នៃរបបសន្តិសុខសង្គម

៤ - ប្រាក់ពិន័យពីការយឺតយូរក្នុងការបង់ភាគទាន ឬការផ្តល់តារាងបៀវត្ស ព្រមទាំងការប្រាក់ពីការយឺតយូរនេះ

៥ - ផលចំណេញដែលបានមកពីការវិនិយោគ

៦ - អំណោយ និងអច្ច័យទានផ្សេងៗ

៧ - ប្រភពធនធានដទៃទៀតដែល ប.ស.ស អាចទទួលបានតាមច្បាប់[៩]។

## ១.៤ កម្មករនិយោជិតក្នុងប្រព័ន្ធ

កម្មករនិយោជិតក្នុងប្រព័ន្ធសំដៅទៅលើជនដែលបានចុះកិច្ចសន្យាការងារ ដើម្បីធ្វើ ឬបម្រើការងារ នៅតាមសហគ្រាស ឬគ្រឹះស្ថាន ឬរោងចក្រណាមួយដោយយកកម្រៃ ហើយបំពេញការងារចាប់ពី៨(ប្រាំបី)ម៉ោងក្នុង១(មួយ)សប្តាហ៍ ធ្វើការងារជាប់លាប់ក្នុងមុខការណាមួយជាអចិន្ត្រៃយ៍ និងត្រូវបានចុះបញ្ជិកាជាសមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គមដូចជា កម្មករ កម្មការិនីដែលបម្រើការងារតាមរោងចក្រកាត់ដេរ ឬរោងចក្រក្នុងតំបន់សេដ្ឋកិច្ចពិសេស សន្តិសុខនៃក្រុមហ៊ុនសន្តិសុខ និងបុគ្គលិកបម្រើការងារតាមសណ្ឋាគារ។ល។

កម្មករនិយោជិតក្នុងប្រព័ន្ធមានសិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ និងតាវកាលិកថែទាំសុខភាពពីបេឡាជាតិរបបសន្តិសុខសង្គមដែលជាកាតព្វកិច្ចរបស់និយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថានក្នុងការបង់ភាគទានផ្នែកហានិភ័យការងារ ហើយកម្មករនិយោជិតក្នុងប្រព័ន្ធអត់តម្រូវឱ្យមានកាតព្វកិច្ចបង់ភាគទានក្នុងផ្នែកនេះនោះទេ[១០]។ ចំណែកឯផ្នែកថែទាំសុខភាពវិញ គឺនិយោជក និងកម្មករនិយោជិតក្នុងប្រព័ន្ធមានកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាពនេះជូនដល់បេឡាជាតិ

[៩] មាត្រា២០ នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[១០] ប្រការ១ នៃប្រកាសលេខ១០៨ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ

របបសន្តិសុខសង្គម[១១] ប៉ុន្តែគិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាពតម្រូវឱ្យស្ថិតក្រោមការទទួលបន្ទុកទាំងស្រុងរបស់និយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថាន[១២]។

សម្រាប់កម្មករនិយោជិតក្នុងប្រព័ន្ធ(កម្មករនិយោជិតជាប់លាប់)នេះផងដែរ ពួកគាត់នឹងទទួលបានអត្ថប្រយោជន៍២(ពីរ)បែប ក្រោយពេលដែលពួកគាត់ត្រូវបានចុះបញ្ជិកាមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម គឺសិទ្ធិទាមទារ និងទទួលបានតាវកាលិកផ្នែកហានិភ័យការងារ និងតាវកាលិកផ្នែកថែទាំសុខភាពដែលជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។

### ១.៤.១. តាវកាលិកហានិភ័យការងារ

នៅពេលដែលកម្មករនិយោជិតក្នុងប្រព័ន្ធជួបប្រទះឧបទ្ទវហេតុ ឬទទួលរងនូវគ្រោះថ្នាក់ណាមួយដែលចាត់ទុកថាជាគ្រោះថ្នាក់ការងារ ឬបណ្តាលមកពីគ្រោះថ្នាក់ការងារ គ្រោះថ្នាក់នៅពេលកំពុងធ្វើដំណើរដោយត្រង់ទៅកន្លែងធ្វើការ ឬមកពីកន្លែងធ្វើការឆ្ពោះទៅលំនៅស្ថាន និងជំងឺវិជ្ជាជីវៈជាដើម ពួកគាត់ជាជនរងគ្រោះផ្ទាល់ ឧត្តរជីវីរបស់ពួកគាត់ ឬអ្នកពាក់ព័ន្ធផ្សេងទៀត មានសិទ្ធិទាមទារ ដើម្បីទទួលបានតាវកាលិកផ្នែកហានិភ័យការងារនេះ ពីខាងបេឡាជាតិរបបសន្តិសុខសង្គម[១៣]។

តាវកាលិកហានិភ័យការងារ ដែលពួកគាត់ខាងលើអាចទទួលបានពីខាងបេឡាជាតិរបបសន្តិសុខសង្គមរួមមាន តាវកាលិកថែទាំ និងព្យាបាល តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ប្រាក់វិភាគបូជាសព និងតាវកាលិកឧត្តរជីវី[១៤]។

---

[១១] មាត្រា៧ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

[១២] មាត្រា៧ ថ្មី នៃអនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

[១៣] ប្រការ១ នៃប្រកាសលេខ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យកាងារ

[១៤] ប្រការ១៣ ដដែល

### ១.៤.២. តាវកាលិកថែទាំសុខភាព

តាវកាលិកថែទាំសុខភាពសម្រាប់កម្មករនិយោជិតក្នុងប្រព័ន្ធ ពួកគាត់នឹងទទួលបាននូវកញ្ចប់តាវកាលិកសុខភាព សំដៅដល់សេវាបញ្ជូនជនរងគ្រោះ សេវាបញ្ជូនសព សេវាព្យាបាលថែទាំវេជ្ជសាស្ត្រមាន(១)ការព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ (២)សេវាពិគ្រោះជំងឺក្រៅ (៣)សេវាសង្គ្រោះបន្ទាន់ (៤)សេវាព្យាបាលដោយស្នំ និងដោយចលនា (៥)សេវាសម្រាលកូន និងសេវាព្យាបាលថែទាំមុននិងក្រោយពេលសម្រាលកូន (៦)សេវាស្តារនីតិសម្បទា និងប្រាក់បំណាច់ប្រចាំថ្ងៃរួមនិងសេវាបង្ការសុខភាពដែលផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម កម្មវិធីជាតិ អង្គភាព ឬស្ថាប័ន និងអង្គការទាក់ទងទៅនឹងបញ្ហាសុខភាពដទៃទៀត[១៥]។

## ១.៥ កម្មករនិយោជិតក្រៅប្រព័ន្ធ

កម្មករនិយោជិតក្រៅប្រព័ន្ធ សំដៅដល់កម្មករនិយោជិតដែលចុះកិច្ចសន្យាធ្វើការងារមួយដែលមានរយៈពេលមួយ មិនលើសប្រាំបីម៉ោង ក្នុងមួយសប្តាហ៍ ធ្វើការងារមួយពេលៗ ធ្វើឈប់ៗ ឬធ្វើការងារមួយរដូវៗ ហើយបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម ជាសមាជិកមូលនិធិ-សមធម៌សុខាភិបាល[១៦]។ ចំណែកឯ អាជីវកម្មគ្រប់វិស័យទាំងឡាយណា ដែលជាថៅកែខ្លួនឯង និងជាបុគ្គលិកខ្លួនឯង ដោយមិននៅក្រោមការគ្រប់ដណ្តប់នៃច្បាប់ស្តីពីការងារនោះទេ ក៏ស្ថិតនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដែរ ហើយពលករទាំងនោះរួមមានជាអាទិ៍ អ្នកលក់ដូរតាមផ្សារ និងដងផ្លូវនានា អ្នកប្រកបរបរធាក់ស៊ីក្លូ រត់រ៉ឺម៉កកង់បី រត់រថយន្តឈ្នួល និងម៉ូតូឌុបជាដើម អ្នកប្រកបរបបកសិកម្មក៏អាចរាប់បញ្ចូលជាពលករនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធផងដែរ។

ចំពោះករណីពួកគាត់ ជាពលករនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងកម្មករនិយោជិតក្រៅប្រព័ន្ធខាងលើនេះ មិនត្រូវបានតម្រូវឱ្យពួកគាត់ ឬនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានរបស់ពួកគាត់បង់ភាគទានមកកាន់បេឡាជាតិរបបសន្តិសុខសង្គម ដូចជាករណីរបស់កម្មករនិយោជិតក្នុងប្រព័ន្ធនោះទេ។ ហើយពួកគាត់ក៏មិនមានសិទ្ធិទាមទារ និងទទួលបាននូវអត្ថប្រយោជន៍ទៅលើផ្នែកហានិភ័យការងារ និងថែទាំសុខភាពដែលផ្តល់ជូនពីបេឡាជាតិរបបសន្តិសុខសង្គមដោយផ្ទាល់ទេ

[១៥] ប្រការ៣ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព

[១៦] ប្រការ៤ នៃប្រកាសអន្តរក្រសួងលេខ៤០៩ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

ដោយពួកគាត់ទទួលបានត្រឹមតែកញ្ចប់តាវកាលិកផ្នែកថែទាំសុខភាពមួយមុខគត់ប៉ុណ្ណោះ ពីប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលដែលកំណត់ដោយក្រសួងសុខាភិបាល[១៧]។ ប៉ុន្តែទៅថ្ងៃមុខ ឬពេលណាមួយ ពួកគាត់ក៏អាចត្រូវបានបញ្ចូលមកក្នុងប្រព័ន្ធរបបសន្តិសុខសង្គម ជាសមាជិកនៃ ប.ស.ស (កម្មករនិយោជិតក្នុងប្រព័ន្ធ)ក៏ថាបាន ព្រោះថាលក្ខខណ្ឌដែលកំណត់អំពីចំនួនកម្មករនិយោជិតចាប់ពី៨(ប្រាំបី)នាក់ឡើង នៃសហគ្រាស គ្រឹះស្ថានណាមួយ ទើបអាចចុះបញ្ជីមកកាន់ ប.ស.ស ត្រូវបានលើកលែង[១៨]។ ដូចនេះ ប្រសិនបើពួកគាត់បំពេញការងារតាមបណ្ដារោងចក្រ ក្រុមហ៊ុនណាមួយ ដោយពិនិត្យឃើញថា ពួកគាត់គ្រប់លក្ខណៈសម្បត្តិអាចជាកម្មករនិយោជិតក្នុងប្រព័ន្ធ ការិយភារី ឬនិយោជក ឬម្ចាស់រោងចក្រ ក្រុមហ៊ុនត្រូវផ្លាស់ប្ដូរការចុះបញ្ជិកាពួកគាត់ពីសមាជិកក្រៅប្រព័ន្ធមកជាសមាជិកក្នុងប្រព័ន្ធនៃ ប.ស.ស។

[១៧] កិច្ចសម្ភាសន៍ផ្ទាល់ជាមួយលោក **សុខ បូរ៉ា** ប្រធានការិយាល័យតាវកាលិកនៃបេឡាជាតិរបបសន្តិសុខសង្គម កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨

[១៨] ប្រការ១៣ នៃប្រកាសលេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាបជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ

## ជំពូកទី២៖ ការចុះបញ្ជិកាកម្មករនិយោជិតក្រៅប្រព័ន្ធ

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនទាំងអស់ដែលស្ថិតនៅក្នុងដែនអនុវត្តន៍នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន និងកម្មករនិយោជិតរបស់ខ្លួនមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបាននូវរបបសន្តិសុខសង្គម។ ដោយឡែកសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធនឹងទទួលបានការថែទាំសុខភាព ពិនិត្យសុខភាព និងព្យាបាលជំងឺដោយឥតគិតថ្លៃតាមមូលដ្ឋានសុខាភិបាលពីប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និងទទួលបានប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រី នៅពេលពួកគាត់សម្រាលកូនទាំងក្នុងនិងក្រៅប្រព័ន្ធ។ អាស្រ័យហេតុនេះ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានដែលមិនទាន់បានចុះបញ្ជីនៅ ប.ស.ស រួសរាន់មកចុះបញ្ជីឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ នៅស្នាក់ការកណ្តាល ប.ស.ស និងតាមសាខា ប.ស.ស ខេត្ត ខណ្ឌ[១៩]។

ក្នុងករណីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនទាំងអស់ ដែលប្រើប្រាស់ការិយភារី ត្រូវមានកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរជាមួយការិយភារី និងត្រូវមានបញ្ជីរាយនាមការិយភារី ដែលខ្លួនបានចុះកិច្ចសន្យាជាមួយ។ ការិយភារីទាំងអស់ត្រូវមានកាតព្វកិច្ចចុះបញ្ជីកម្មករនិយោជិត ដែលខ្លួនប្រើប្រាស់មកក្នុងបេឡាជាតិរបបសន្តិសុខសង្គមផងដែរ[២០]។

ដោយឡែកចំពោះអង្គការ សមាគមនៃការងារក្រៅប្រព័ន្ធ សាលាក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តទាំងអស់ ដើម្បីអនុញ្ញាតឱ្យសមាជិកនៃសមាគម សមាជិកភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ និងកីឡាករ កីឡាការិនីទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនពីរាជរដ្ឋាភិបាល ក៏តម្រូវឱ្យអង្គភាពទាំងនោះមកធ្វើការបំពេញបែបបទ ទម្រង់នៃការចុះបញ្ជិកាជាមុនសិននៅក្នុងបេឡាជាតិរបបសន្តិសុខសង្គមដូចគ្នា។

---

[១៩] សេចក្តីជូនដំណឹងលេខ៣៣៦ ក.ប/ស.ជ.ណ.ប.ស.ស ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបានការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន

[២០] ប្រការ១១ នៃប្រកាសអន្តរក្រសួងលេខ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

## ២.១. បញ្ជិកាសហគ្រាស គ្រឹះស្ថាន អង្គការ សមាគមនៃការងារក្រៅប្រព័ន្ធ សាលាក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

ការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន អង្គការ សមាគមនៃការងារក្រៅប្រព័ន្ធ សាលាក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត តម្រូវឱ្យនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ប្រធាន ឬអនុប្រធានការិយាល័យរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ប្រធាន ឬអនុប្រធានការិយាល័យរដ្ឋបាលមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងប្រធាន ឬអនុប្រធានអង្គការសមាគមនានានៃការងារក្រៅប្រព័ន្ធដែលជាអ្នកតំណាងមកធ្វើការបំពេញសំណុំបែបបទតាមទម្រង់ «បញ្ជិកាសហគ្រាស គ្រឹះស្ថាន» ឬហៅថាទម្រង់ «១.០១» ដែលមានចែងក្នុងឧបសម្ព័ន្ធ១ នៃប្រកាសលេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ឬអ្នកតំណាង ប្រធាន ឬអនុប្រធានអង្គការសមាគមនានានៃការងារក្រៅប្រព័ន្ធត្រូវភ្ជាប់មកជាមួយទម្រង់ «១.០១» នូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងវិញ្ញាបនបត្របញ្ជិកាពាណិជ្ជកម្ម ដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬលិខិតនៃការចុះអនុស្សារណៈដោយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ឬប្រកាសស្តីពីការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលចេញដោយក្រសួងមហាផ្ទៃ ឬលិខិតតូបករណ៍គតិយុត្តសមមូលដទៃទៀត[២១]។ ចំពោះសាលាក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តវិញ នៅពេលដែលមកចុះបញ្ជិកាអង្គភាព ស្ថាប័នរបស់ខ្លួន ក៏តម្រូវឱ្យភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណអភិបាល ឬអភិបាលរងក្រុង ស្រុក ខណ្ឌ១(មួយ)រូប និងអត្តសញ្ញាណប័ណ្ណប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត១(មួយ)រូបផងដែរ។ ដើម្បីទទួលនូវលេខកូដសម្គាល់សហគ្រាស គ្រឹះស្ថាន ឬសមាគម អង្គការក្រៅរដ្ឋាភិបាល ឬអង្គភាព ស្ថាប័នរបស់ខ្លួនមុនធ្វើការចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធ ឬកីឡាករ និងកីឡាការិនីអាជីព ឬសមាជិកភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់។

[២១] ប្រការ៦ នៃប្រកាសលេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## ២.២. បញ្ជិកាកម្មករនិយោជិតក្រៅប្រព័ន្ធ

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះកម្មករនិយោជិតក្នុងពេលដំណាលគ្នា និងទម្រង់បញ្ជិកាសហគ្រាស គ្រឹះស្ថាន។ ក្នុងករណីខកខាន មិនបានចុះបញ្ជីនោះទេ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន រោងចក្រត្រូវធ្វើការទទួលខុសត្រូវចំពោះមុខច្បាប់ ជាពិសេសត្រូវទទួលខុសត្រូវលើការផ្តល់នូវអត្ថប្រយោជន៍ជូនដល់បុគ្គលិក និងកម្មករនិយោជិតដែលខ្លួនកំពុងប្រើប្រាស់មានដូចជាសេវាមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន[២២]។

នីតិវិធី និងបែបបទនៃការចុះបញ្ជិកាកម្មករនិយោជិតក្រៅប្រព័ន្ធ មកក្នុងបេឡាជាតិរបបសន្តិសុខសង្គមត្រូវធ្វើឡើង ដោយត្រូវបំពេញតាមទម្រង់សលាកប័ត្រព័ត៌មានកម្មករនិយោជិត ឬហៅថាទម្រង់ «១.០២» ដូចមានចែកក្នុងឧបសម្ព័ន្ធ២ នៃប្រកាសលេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដូចកម្មករនិយោជិតក្នុងប្រព័ន្ធផងដែរ។

ដើម្បីអាចចុះបញ្ជិកាមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម(មូលនិធិសមធម៌សុខាភិបាល) ជាចាំបាច់ណាស់កម្មករនិយោជិតក្រៅប្រព័ន្ធត្រូវមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ[២៣] និងបានកំពុងបម្រើការងារនៅតាមបណ្តាសហគ្រាស គ្រឹះស្ថានណាមួយកន្លែង ដែលបំពេញការងារមិនលើសពី៨(ប្រាំបី)ម៉ោងក្នុង១(មួយ)សប្តាហ៍ ទើប ប.ស.ស អាចចេញប័ណ្ណសមាជិកនៃមូលនិធិសមធម៌សុខាភិបាលជូនដល់ពួកគាត់ ក្នុងករណីដែលពួកគាត់ធ្វើការងារចាប់ពី៨(ប្រាំបី)ម៉ោងលើរយៈពេល១(មួយ)សប្តាហ៍ គឺនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវចុះបញ្ជិកាពួកគាត់ទៅក្នុងប្រព័ន្ធរបស់បេឡាជាតិរបបសន្តិសុខសង្គម ជាកម្មករនិយោជិតក្នុងប្រព័ន្ធ។

---

[២២] សេចក្តីជូនដំណឹងលេខ៣៣៦ ក.ប/ស.ជ.ណ.ប.ស.ស ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបានការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន

[២៣] ប្រការ៨ នៃប្រកាសលេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## ២.៣. បញ្ជិកាសមាជិកនៃអង្គការ សមាគមនានានៃការងារក្រៅប្រព័ន្ធ

អ្នកប្រកបរបររត់ម៉ូតូឌុប រ៉ឺម៉កកង់បី ស៊ីក្លូ និងរថយន្តឈ្នួលក៏ទទួលបានអត្ថប្រយោជន៍ដូចជាកម្មករនិយោជិតក្រៅប្រព័ន្ធផ្សេងទៀតដែលពួកគាត់មិនបម្រើការងារក្នុងសហគ្រាស គ្រឹះស្ថានឱ្យនិយោជក ឬថៅកែណាមួយនោះទេ ដោយប្រកបរបរផ្ទាល់ខ្លួនតាមផ្សារ ឬដងផ្លូវដែលជាថៅកែនិងជានិយោជិតផង ដោយខ្លួនឯងតែម្តង កម្មករស៊ីឈ្នួលលីសែងឥវ៉ាន់នៅតាមផ្សារ និងកំពង់ផែជាដើមដោយបញ្ចេញកម្លាំង និងប្រើប្រាស់សម្ភារៈ ឬរបស់របរ(មធ្យោបាយ)ខ្លួនឯងផ្ទាល់។ល។

ពេលដែលពួកគាត់មានតែម្នាក់ៗឯងរាយប៉ាយគ្នា ដោយមិនស្ថិតក្នុងសហគ្រាស គ្រឹះស្ថាន ឬអង្គការ សមាគមក្រៅរដ្ឋាភិបាលណាមួយ ពិតជាមានការពិបាកណាស់ ចំពោះបេឡាជាតិរបបសន្តិសុខសង្គមក្នុងការកំណត់អត្តសញ្ញាណ និងប្រមូលពួកគាត់មកធ្វើការចុះបញ្ជី។ ដូចនេះ ដើម្បីអនុញ្ញាតឱ្យពួកគាត់អាចចុះបញ្ជិកាចូលក្នុងបេឡាជាតិរបបសន្តិសុខសង្គមបាន ពួកគាត់ចាំបាច់ត្រូវបំពេញលក្ខខណ្ឌដោយចូលជាសមាជិកនៃអង្គការ ឬសមាគមនានានៃការងារក្រៅប្រព័ន្ធជាមុនសិន ដូចជាសមាគមម៉ូតូឌុប សមាគមស៊ីក្លូ សមាគមរ៉ឺម៉កកង់បីជាដើម ទើបបេឡាជាតិរបបសន្តិសុខសង្គមអាចធ្វើការចេញប័ណ្ណមូលនិធិសមធម៌សុខាភិបាលជូនពួកគាត់បាន និយាយរួមពួកគាត់មិនអាចចុះបញ្ជិកា ដោយខ្លួនមិនមានភាពជាសមាជិកនៃអង្គការ សមាគមនៃការងារក្រៅប្រព័ន្ធណាមួយនោះទេ។

គោលបំណងនៃការកំណត់ដូចនេះ ដើម្បីបង្កើតឱ្យមានជាអង្គការ សមាគមដែលឈរក្នុងភាពជាតំណាងមួយរបស់ពួកគាត់សម្រាប់ងាយស្រួលក្នុងការប្រមូល និងរៀបចំបញ្ជូនបញ្ជីឈ្មោះសមាជិក សមាជិការបស់ខ្លួនមកចុះបញ្ជិកា ជាកម្មករនិយោជិតក្រៅប្រព័ន្ធមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម។

## ២.៤. បញ្ជិកាសមាជិកភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់

សមាជិកភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីអាចធ្វើប័ណ្ណមូលនិធិសមធម៌សុខាភិបាលដំបូងពួកគាត់ត្រូវរៀបចំបញ្ជីឈ្មោះរបស់ពួកគាត់ពីថ្នាក់ភូមិ មកថ្នាក់ឃុំ សង្កាត់ រួចបញ្ជូនបញ្ជីឈ្មោះនោះ មកកាន់សាលាក្រុង ស្រុក ខណ្ឌជាមុនសិន និងដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណ-ប័ណ្ណសញ្ជាតិខ្មែរ នៃសមាជិកភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ម្នាក់ៗផងដែរ។ បន្ទាប់មកទើបអភិបាល ឬអភិបាលរង ឬតំណាងរបស់សាលាក្រុង ស្រុក ខណ្ឌដែលអាចជាប្រធាន ឬអនុប្រធាន

ការិយាល័យរដ្ឋបាល១(មួយ)រូបបញ្ជូនបញ្ជីឈ្មោះសមាជិកភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះមកធ្វើការចុះបញ្ជីក្នុងបេឡាជាតិរបបសន្តិសុខសង្គម។

## ២.៥. បញ្ជិកាកីឡាករ និងកីឡាការិនីអាជីព

ចំណែកកីឡាករ កីឡាការិនីអាជីពវិញ ក៏មិនខុសប្លែកអ្វីពីសមាជិកភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់នោះទេ។ មុននឹងធ្វើការចុះបញ្ជិកាបាន ពួកគាត់ត្រូវទៅចុះឈ្មោះនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដើម្បីខាងមន្ទីររៀបចំបញ្ជីឈ្មោះរបស់ពួកគាត់ បន្ទាប់មកទើបមន្ទីរបញ្ជូនមកធ្វើការចុះបញ្ជីនៅសាខា ប.ស.ស ប្រចាំខេត្ត និងខណ្ឌ ឬមកកាន់ទីស្នាក់ការកណ្តាលបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីចេញប័ណ្ណមូលនិធិ-សមធម៌សម្រាប់អនុញ្ញាតឱ្យពួកគាត់យកទៅប្រើប្រាស់ នៅពេលដែលពួកគាត់ទទួលសេវាពិនិត្យព្យាបាល និងថែទាំសុខភាពតាមមូលដ្ឋានសុខាភិបាល[២៤]។

ជារួមពេលណាដែលនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ប្រធាន ឬអនុប្រធានការិយាល័យរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ប្រធាន ឬអនុប្រធានការិយាល័យរដ្ឋបាលមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងប្រធាន ឬអនុប្រធានសមាគមនានានៃការងារក្រៅប្រព័ន្ធដែលជាអ្នកតំណាងឱ្យកម្មករនិយោជិតក្រៅប្រព័ន្ធ ឬកីឡាករ និងកីឡាការិនីអាជីព ឬសមាជិកភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់ ចង់មកធ្វើការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ឬសមាគម អង្គការក្រៅរដ្ឋាភិ-បាល ឬសាលាក្រុង ស្រុក ខណ្ឌ និងមន្ទីររបស់ខ្លួនក្នុងបេឡាជាតិរបបសន្តិសុខសង្គម ពួកគាត់អាចអញ្ជើញទៅធ្វើការចុះបញ្ជីនៅទីស្នាក់ការកណ្តាលនៃបេឡាជាតិរបបសន្តិសុខសង្គម ឬតាមបណ្តាសាខា ប.ស.ស ប្រចាំខេត្ត និងខណ្ឌណាមួយដែលមានទីតាំងនៅជិតសហគ្រាស គ្រឹះស្ថាន ឬអង្គ-ការ សមាគម ឬអង្គភាព ស្ថាប័នរបស់ពួកគាត់បានដូចខាងក្រោម៖

ក. ទីស្នាក់ការកណ្តាលរបស់បេឡាជាតិរបបសន្តិសុខសង្គម:

អាសយដ្ឋាន: អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ (បរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)

លេខទូរស័ព្ទទំនាក់ទំនង: ០២៣ ៨៨២ ៩៣៩

វេបសាយ: www.nssf.gov.kh

[២៤] កិច្ចសម្ភាសន៍ផ្ទាល់ជាមួយលោកស្រី **ស៊ឹម ស៊ុនណារី** អនុប្រធានការិយាល័យបញ្ជិកា និងភាគទាននៃបេឡាជាតិរបបសន្តិសុខសង្គម កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨

ខ. សាខា ប.ស.ស ប្រចាំខេត្ត និងខណ្ឌៈ

១. សាខា ប.ស.ស ខេត្តកណ្ដាល

អាសយដ្ឋានៈ ផ្ទះលេខ០១ ផ្លូវលេខ២០២ ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល

លេខទូរស័ព្ទទំនាក់ទំនងៈ ០២៤ ៦៤០ ១៦៧៦

២. សាខា ប.ស.ស ខេត្តកំពង់ស្ពឺ

អាសយដ្ឋានៈ ផ្ទះលេខ៣៦អេ ភូមិស្វាយជ្រុំ ឃុំបែកចាន ស្រុកបែកចាន ខេត្តកំពង់ស្ពឺ

លេខទូរស័ព្ទទំនាក់ទំនងៈ ០២៤ ៦៨៨ ០០៩៧

៣. សាខា ប.ស.ស ខេត្តព្រះសីហនុ

អាសយដ្ឋានៈ ភូមិ០២ សង្កាត់លេខ០៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

លេខទូរស័ព្ទទំនាក់ទំនងៈ ០៣៤ ៩៣៤ ៦០៦

៤. សាខា ប.ស.ស ខេត្តស្វាយរៀង

អាសយដ្ឋានៈ ផ្លូវជាតិលេខ០១ ភូមិបាវិតលើ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង

លេខទូរស័ព្ទទំនាក់ទំនងៈ ០៤៤ ៧១៥ ៨៣១

៥. សាខា ប.ស.ស ខេត្តកំពង់ឆ្នាំង

អាសយដ្ឋានៈ ផ្ទះលេខ៤៩៥សេ ភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

លេខទូរស័ព្ទទំនាក់ទំនងៈ ០២៦ ៩៨៨ ៨៩១

៦. សាខា ប.ស.ស ខេត្តសៀមរាប

អាសយដ្ឋានៈ ភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប

លេខទូរស័ព្ទទំនាក់ទំនងៈ ០៦៣ ៩៦៥ ៩៣៤

៧. សាខា ប.ស.ស ខេត្តបន្ទាយមានជ័យ

អាសយដ្ឋាន: ភូមិគីឡូម៉ែត្រលេខ០៤ សង្កាត់កំពង់ស្វាយ ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ

លេខទូរស័ព្ទទំនាក់ទំនង: ០៥៤ ៩៦៧ ៤៤៩

៨. សាខា ប.ស.ស ខេត្តកំពង់ចាម

អាសយដ្ឋាន: ភូមិ០៤ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម

លេខទូរស័ព្ទទំនាក់ទំនង: ០៤២ ៦៥២ ១៩៩៩

៩. សាខា ប.ស.ស ខេត្តព្រៃវែង

អាសយដ្ឋាន: ផ្ទះលេខ១០៧ ភូមិ០៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង

លេខទូរស័ព្ទទំនាក់ទំនង: ០១២ ៥៤៨ ៨០៥

១០. សាខា ប.ស.ស ខេត្តតាកែវ

អាសយដ្ឋាន: ផ្លូវលេខ១០ ភូមិ០២ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ

លេខទូរស័ព្ទទំនាក់ទំនង: ០៣២ ៦៤០ ២៤២៩

១១. សាខា ប.ស.ស ខេត្តស្ទឹងត្រែង

អាសយដ្ឋាន: ភូមិថ្មលាត សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

លេខទូរស័ព្ទទំនាក់ទំនង: ០១២ ៤០៥ ៤៥១

១២. សាខា ប.ស.ស ខេត្តក្រចេះ

អាសយដ្ឋាន: ភូមិរកាកណ្តាលទី០១ សង្កាត់រកាកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ

លេខទូរស័ព្ទទំនាក់ទំនង: ០៩២ ៨៧៣ ០៥១

១៣. សាខា ប.ស.ស ខេត្តកំពត

អាសយដ្ឋាន: ភូមិ០១ ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត

លេខទូរស័ព្ទទំនាក់ទំនង: ០៣៣ ៩៣២ ១៣៣

១៤. សាខា ប.ស.ស ខេត្តពោធិ៍សាត់

អាសយដ្ឋាន: ផ្ទះលខ០០៧ ភូមិរ៉ា សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

លេខទូរស័ព្ទទំនាក់ទំនង: ០៥២ ៩៥១ ១២៣

១៥. សាខា ប.ស.ស ខេត្តបាត់ដំបង

អាសយដ្ឋាន: ផ្ទះលេខ០៩បេ បូរីពាណិជ្ជកម្មបាត់ដំបង ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

លេខទូរស័ព្ទទំនាក់ទំនង: ០៥៣ ៩៥៣ ៣៣៦

១៦. សាខា ប.ស.ស ខេត្តកោះកុង

អាសយដ្ឋាន: ផ្ទះលេខ២៦ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង

លេខទូរស័ព្ទទំនាក់ទំនង: ០៣៥ ៩៣៦ ៤៣៦

១៧. សាខា ប.ស.ស ខេត្តប៉ៃលិន

អាសយដ្ឋាន: ភូមិវត្ត សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន

លេខទូរស័ព្ទទំនាក់ទំនង: ០៥៥ ៩៥៦ ៦៦៧

១៨.សាខា ប.ស.ស ខេត្តកំពង់ធំ

អាសយដ្ឋាន: ភូមិ០៧ សង្កាត់កំពង់ធំ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ

លេខទូរស័ព្ទទំនាក់ទំនង: ០៦២ ២១០ ៥៦៣

១៩. សាខា ប.ស.ស ខេត្តរតនគិរី

អាសយដ្ឋាន: ភូមិអូរកន្ដិល សង្កាត់បឹងកន្សែង ក្រុងបាលុង ខេត្តរតនគិរី

លេខទូរស័ព្ទទំនាក់ទំនង: ០១១ ៩៥១ ៧៧៧

២០. សាខា ប.ស.ស ខេត្តមណ្ឌលគិរី

អាសយដ្ឋាន: ភូមិចំបក់ សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី

លេខទូរស័ព្ទទំនាក់ទំនង: ០១២ ២០៥ ៧៥៦

២១. សាខា ប.ស.ស ខេត្តឧត្តរមានជ័យ

អាសយដ្ឋាន: ភូមិឈូក សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ

លេខទូរស័ព្ទទំនាក់ទំនង: ០៩៧ ៥២៣ ៤៦៦៦

២២. សាខា ប.ស.ស ខេត្តព្រះវិហារ

អាសយដ្ឋាន: ភូមិកណ្តាល សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ

លេខទូរស័ព្ទទំនាក់ទំនង: ០៩៧ ៣៦៦ ៦០៦០

២៣. សាខា ប.ស.ស ខណ្ឌដង្កោ

អាសយដ្ឋាន: ផ្ទះលេខ១១២អេ ផ្លូវវេងស្រេង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទទំនាក់ទំនង: ០១២ ៦៩៥ ៥៥០

២៤.សាខា ប.ស.ស ខណ្ឌឫស្សីកែវ

អាសយដ្ឋាន: ផ្ទះលេខ៥០អឺ០អឺ1 ផ្លូវលេខ០៣ ភូមិបឹងឈូក សង្កាត់គីឡូម៉ែត្រ០៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

លេខទូរស័ព្ទទំនាក់ទំនង: ០៩២ ៤៨៦ ២៥៦[២៥]។

ចាប់តាំងពីផ្តើមបើកការចុះបញ្ជិកាហូតមកដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨ បេឡាជាតិរបបសន្តិសុខសង្គមបានចុះបញ្ជីសហគ្រាស គ្រឹះស្ថាន អង្គការ សមាគមនៃការងារក្រៅប្រព័ន្ធសាលាក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសរុបចំនួន៨៨៩(ប្រាំបីរយប៉ែតសិបប្រាំបួន)សហគ្រាស គ្រឹះស្ថាន អង្គការ សមាគម និងអង្គភាព ស្ថាប័ន និងចេញប័ណ្ណមូលនិធិសមធម៌សុខាភិបាលជូនដល់កម្មករនិយោជិតក្រៅប្រព័ន្ធ សមាជិកភូមិ និងក្រុមប្រឹក្សាឃុំសង្កាត់ និងកីឡាករ និងកីឡាការិនីអាជីពសរុបចំនួនប្រមាណ៧៣,៤៧០(ប្រាំពីរម៉ឺនបីពាន់បួនរយចិតសិប)នាក់ ស្រី១៥,៨៦០(មួយម៉ឺនប្រាំពាន់ប្រាំបីរយហុកសិប)នាក់[២៦]។

## ២.៦. ប័ណ្ណមូលនិធិសមធម៌សុខាភិបាលក្នុងក្របខ័ណ្ឌបេឡាជាតិរបបសន្តិសុខសង្គម

[២៥] http://www.nssf.gov.kh/default

[២៦] កិច្ចសម្ភាសន៍ផ្ទាល់ជាមួយលោកស្រី **ស៊ឹម ស៊ុនណារី** អនុប្រធានការិយាល័យបញ្ជិកា និងភាគទាននៃបេឡាជាតិរបបសន្តិសុខសង្គម កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨

នៅពេលណាពួកគាត់ត្រូវបានចុះបញ្ជិកា ជាកម្មករនិយោជិតក្រៅប្រព័ន្ធ(សមាជិកមូលនិធិសមធម៌សុខាភិបាល)រួចហើយ ទើបបេឡាជាតិរបបសន្តិសុខសង្គមធ្វើការចេញប័ណ្ណមូលនិធិសមធម៌សុខាភិបាលដល់ពួកគាត់ ក្នុងអំឡុងរយៈពេល១(មួយ)សប្តាហ៍ទៅ១០(ដប់)ថ្ងៃយ៉ាងយូរ ដោយគិតចាប់ពីពេលដែលខាង ប.ស.ស ទទួលបានសលាកប័ត្រព័ត៌មានកម្មករនិយោជិត ដោយមិនមានការបង់កម្រៃថ្លៃប័ណ្ណនោះទេ។

សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធនេះផ្ទាល់តែម្តង់ គឺពួកគាត់នឹងទទួលបានប័ណ្ណមូលនិធិសមធម៌សុខាភិបាលពណ៌លឿង ចំណែកឯសមាជិកភូមិនិងក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ដូចជាកីឡាករ និងកីឡាការិនីអាជីព ពួកគាត់នឹងទទួលបានប័ណ្ណពណ៌ស្វាយ ពីបេឡាជាតិរបបសន្តិសុខសង្គម។ បើទោះបីជាប័ណ្ណមូលនិធិសមធម៌សុខាភិបាលនេះ បានផ្តល់ទៅឱ្យសមាជិកមាន២(ពីរ)ពណ៌ខុសគ្នាក៏ពិតមែន ប៉ុន្តែប័ណ្ណនេះ ក៏មិនមានអ្វីខុសប្លែកគ្នាក្នុងក្របខ័ណ្ឌនៃអត្ថប្រយោជន៍ការប្រើប្រាស់ ឬជាលក្ខណៈទម្រង់នោះទេ គឺគ្រាន់ជាការកំណត់សម្គាល់តែប៉ុណ្ណោះ[២៧]។

ក. នៅលើផ្នែកខាងមុខរបស់ប័ណ្ណមានដាក់បាវចនាជាតិ និងសរសេរកំណត់បញ្ជាក់អំពីព័ត៌មានមួយចំនួនដូចជា៖

១. ប័ណ្ណមូលនិធិសមធម៌សុខាភិបាលប្រើប្រាស់បានតែមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ

២. អ្នកកាន់ប័ណ្ណនេះត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សេវាថែទាំសុខភាពដោយឥតគិតថ្លៃ

៣. ការប្រើប្រាស់សេវាសុខាភិបាលត្រូវចាប់ផ្តើមពីមណ្ឌលសុខភាព

៤. ការប្រើប្រាស់សេវានៅមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងមន្ទីរពេទ្យជាតិ ត្រូវមានលិខិតបញ្ជូនពីមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត លើកលែងករណីត្រូវសង្គ្រោះបន្ទាន់

៥. រាល់ពេលប្រើប្រាស់សេវាត្រូវបង្ហាញប័ណ្ណនេះ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដល់បុគ្គលិកមណ្ឌលសុខភាព និងមន្ទីរពេទ្យ

៦. ក្នុងករណីខូច ឬបាត់ សាមីជនត្រូវស្នើសុំទុតិយតានៅបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូរ៣០(សាមសិប)ថ្ងៃ

[២៧] https://www.youtube.com/watch?v=7-gSNzFV0f4

៧. ជនណាក្លែងបន្លំប័ណ្ណនេះ នឹងត្រូវផ្តន្ទាទោសតាមច្បាប់។

ខ. រីឯផ្នែកខាងក្រោយ គឺជាទិន្នន័យរបស់សាមីជនៈ

១. លេខអត្តសញ្ញាណសាមីជន

២. គោត្តនាម និងនាមសាមីជនជាខ្មែរ និងឡាតាំង

៣. ថ្ងៃខែឆ្នាំកំណើត និងភេទ

៤. QR Cord (ឃ្យូអ៊ែរកូដ)

៥. កាលបរិច្ឆេទផុតកំណត់ប្រើប្រាស់ប័ណ្ណ(សុពលភាព)

៦. ហត្ថលេខានាយក ដោយប្រថាប់ត្រារបស់ ប.ស.ស ។

រាល់គ្រប់ប័ណ្ណមូលនិធិសមធម៌សុខាភិបាលទាំងអស់ទោះពណ៌លឿង ឬពណ៌ស្វាយក្តី គឺមានសុពលភាពប្រើប្រាស់ត្រឹមតែរយៈពេល១(មួយ)ឆ្នាំប៉ុណ្ណោះ គិតចាប់ពីកាលបរិច្ឆេទនៃការចេញប័ណ្ណ[២៨] ប៉ុន្តែយើងសូមធ្វើការគូសបញ្ជាក់ផងដែរថា ការផ្តល់តាវកាលិកថែទាំសុខភាពចំពោះកម្មករនិយោជិតក្រៅប្រព័ន្ធ សមាជិកនៃអង្គការ សមាគមនានានៃការងារក្រៅប្រព័ន្ធ សមាជិកភូមិនិងក្រុមប្រឹក្សាឃុំ សង្កាត់ និងកីឡាករ កីឡាការិនីអាជីព បូករួមនិងប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនចំពោះកម្មករនិយោជិតជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ ត្រូវចាប់ផ្តើមដាក់ឱ្យអនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ[២៩]។

ក្នុងករណីប័ណ្ណមូលនិធិសមធម៌សុខាភិបាលខូច ឬបាត់ សាមីជនម្ចាស់ប័ណ្ណត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដើម្បីឱ្យខាង និយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថានបញ្ជូនឈ្មោះកម្មករនិយោជិតក្រៅប្រព័ន្ធរបស់ពួកគាត់មកខាងបេឡាជាតិរបបសន្តិសុខសង្គម ក្នុងការស្នើសុំទុតិយតាប័ណ្ណ ក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទ

[២៨] កិច្ចសម្ភាសន៍ផ្ទាល់ជាមួយលោក **សុខ បូរ៉ា** ប្រធានការិយាល័យតាវកាលិកនៃបេឡាជាតិរបបសន្តិសុខសង្គម កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨

[២៩] ប្រការ១៤ នៃប្រកាសអន្តរក្រសួងលេខ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

នៃការជូនដំណឹងខាងលើ សម្រាប់ពួកគាត់ជាកម្មករនិយោជិតក្រៅប្រព័ន្ធបានទទួលប័ណ្ណទុតិយតាយកទៅប្រើប្រាស់ជាប្រយោជន៍។

រីឯសមាជិកនៃអង្គការ សមាគមនានានៃការងារក្រៅប្រព័ន្ធ សមាជិកភូមិនិងក្រុមប្រឹក្សាឃុំសង្កាត់ និងកីឡាករ កីឡាការិនីអាជីពក៏មិនមានអ្វីខុសប្លែកគ្នាពីកម្មករនិយោជិតក្រៅប្រព័ន្ធនោះដែរ នៅពេលមានការខូច ឬបាត់ប័ណ្ណ ពួកគាត់ត្រូវផ្តល់ដំណឹងមកកាន់ស្ថាប័ន អង្គភាពសាមីដែលបានធ្វើការរៀបចំស្នើសុំប័ណ្ណមូលនិធិសមធម៌សុខាភិបាលជូនគាត់ពីពេលមុន តាមបែបបទ និងនីតិវិធីដែលបានកំណត់សម្រាប់ស្ថាប័ន អង្គភាពនីមួយៗ ក្នុងការឱ្យស្ថាប័ន អង្គភាពរៀបចំបញ្ជីឈ្មោះរបស់ពួកគាត់ ដែលជាអ្នកបាត់ប័ណ្ណដាក់ស្នើសុំទុតិយតាប័ណ្ណមកកាន់ ប.ស.ស ដើម្បីចេញប័ណ្ណ-ទុតិយតា ឱ្យពួកគាត់ក្នុងរយៈពេល១(មួយ)សប្តាហ៍ទៅ១០(ដប់)ថ្ងៃ ឬក្នុងករណីដែលពួកគាត់ត្រូវយកទៅប្រើប្រាស់បន្ទាន់ គឺខាង ប.ស.ស នឹងជួយសម្រួលក្នុងការចេញប័ណ្ណជូនពួកគាត់ឱ្យបានលឿនជាទីបំផុតតាមដែលអាចធ្វើទៅបាន ដោយមិនមានការបង់ថ្លៃនោះទេ[៣០]។

[៣០] កិច្ចសម្ភាសន៍ផ្ទាល់ជាមួយលោកស្រី **ស៊ឹម ស៊ុនណារី** អនុប្រធានការិយាល័យបញ្ជិកា និងភាគទាននៃបេឡាជាតិរបបសន្តិសុខសង្គម កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨

# ជំពូកទី៣៖ អត្ថប្រយោជន៍នៃប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល

កម្មករនិយោជិតក្រៅប្រព័ន្ធ សមាជិកនៃអង្គការ សមាគមនានានៃការងារក្រៅប្រព័ន្ធ សមាជិកភូមិនិងក្រុមប្រឹក្សាឃុំ សង្កាត់ និងកីឡាករ កីឡាការិនីអាជីព ពួកគាត់ទាំងអស់នោះហើយ នឹងទទួលបានការផ្តល់អត្ថប្រយោជន៍តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សំដៅដល់យន្តការហិរញ្ញប្បទានផ្នែកគាំពារសុខភាពសង្គម ដើម្បីផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋជាក្រុមគោលដៅមួយចំនួនទទួលបាន ឬប្រើប្រាស់សេវាថែទាំ ពិនិត្យ និងព្យាបាលសុខភាព ដោយឥតមានការបង់ថ្លៃនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ដែលរាជរដ្ឋាភិបាលជាអ្នកទទួលបន្ទុកបង់ថ្លៃជំនួស[៣១] ដែលផ្តល់ជូនពួកគាត់តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយមានបេឡាជាតិរបបសន្តិ-សុខសង្គម ជាសេនាធិការលើការចុះបញ្ជិកា និងចេញប័ណ្ណសមាជិកនៃមូលនិធិសមធម៌សុខាភិបាលដល់ពួកគាត់[៣២] រួមជាមួយនិងក្រសួងសុខាភិបាលដោយមានមណ្ឌលសុខភាព និងមន្ទីរពេទ្យរបស់រដ្ឋទូទាំងប្រទេស ជាសេនាធិការក្នុងការអនុវត្តរបបនេះ[៣៣]។

ការចំណាយលើការផ្តល់សេវាថែទាំសុខភាព សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនត្រូវហិរញ្ញប្បទានដោយថវិការដ្ឋ។ ឥណទានថវិកានេះ គឺត្រូវតែគ្រោងដាច់ដោយឡែកពីឥណទានមូលនិធិសមធម៌សុខាភិ-បាលសម្រាប់ប្រជាពលរដ្ឋក្រីក្រ[៣៤]។

## ៣.១. មូលដ្ឋានសុខាភិបាល

ចំពោះមូលដ្ឋានសុខាភិបាលក្នុងន័យនេះ គឺយើងសំដៅទៅដល់មណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋនានា ដែលជាមូលដ្ឋានសុខាភិបាលសាធារណៈទាំង៣(បី)ថ្នាក់រួមមាន ថ្នាក់ទី១(មួយ) មណ្ឌលសុខភាព ថ្នាក់ទី២(ពីរ) មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែករាជធានី ខេត្ត

[៣១] ប្រការ៥ នៃប្រកាសអន្តរក្រសួងលេខ៨០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

[៣២] ប្រការ៥ ដដែល

[៣៣] ប្រការ៦ ដដែល

[៣៤] ប្រការ១៣ ដដែល

ដែលហៅថាមូលដ្ឋានសុខាភិបាលថ្នាក់ទាប និងថ្នាក់ទី៣(បី) មន្ទីរពេទ្យជាតិ ជាមូលដ្ឋានសុខាភិបាលថ្នាក់ខ្ពស់ តាមប្រព័ន្ធនៃការផ្តល់សេវាសុខាភិបាលសាធារណៈ[៣៥]។

## ៣.២. តាវកាលិកថែទាំសុខភាព និងប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូន

នៅពេលឈឺ ឬមានបញ្ហាសុខភាពម្តងៗ មុនពេលរាជរដ្ឋាភិបាលបានគិតគូរដាក់ចេញនូវរបបថែទាំសុខភាពដោយឥតបង់ថ្លៃនេះ តាមរយៈប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល ឈរលើគោលនយោបាយជាតិគាំពារសង្គម ដើម្បីជួយសម្រាលសម្រួលដល់បន្ទុកជីវភាពរស់នៅប្រចាំថ្ងៃរបស់កម្មករនិយោជិតដែលបំពេញការងារតិចជាង៨(ប្រាំបី)ម៉ោងក្នុង១(មួយ)សប្តាហ៍ សមាជិកនៃអង្គការ សមាគមនានានៃការងារក្រៅប្រព័ន្ធ សមាជិកភូមិនិងក្រុមប្រឹក្សាឃុំ សង្កាត់ និងកីឡាករកីឡាការិនីអាជីព រាល់ពេលទៅទទួលសេវាថែទាំសុខភាព នៅមូលដ្ឋានសុខាភិបាល គឺពួកគាត់ត្រូវបង់ថ្លៃរាល់គ្រប់ចំណាយលើការពិនិត្យ និងសម្រាកព្យាបាលជំងឺផ្ទាល់ខ្លួន។ ប៉ុន្តែក្រោយពីទទួលបានការគិតគូរពីរាជរដ្ឋាភិបាលមក គឺពួកគាត់មិនចាំបាច់ចំណាយថវិកាលើផ្នែកនេះបន្តទៀតទេពេលពួកគាត់មកទទួលសេវាថែទាំសុខភាពពីមូលដ្ឋានសុខាភិបាល រួមបញ្ចូលនិងអត្ថប្រយោជន៍មួយទៀត ដែលពួកគាត់ត្រូវទទួលបានចំពោះកម្មករនិយោជិតជានារីទោះក្នុងប្រព័ន្ធ ឬក្រៅប្រព័ន្ធក្តីសម្រាប់ប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូន[៣៦]។

### ៣.២.១. តាវកាលិកថែទាំសុខភាពនៃកម្មករនិយោជិតក្រៅប្រព័ន្ធ

តាវកាលិកថែទាំសុខភាពផ្នែកមូលនិធិសមធម៌សុខាភិបាល សំដៅដល់សេវាព្យាបាល និងថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល[៣៧]។ កាលណាពួកគាត់ជាកម្មករនិយោជិតដែលមានការងារមិនជាប់លាប់(មិនអចិន្ត្រៃយ៍) ហើយរាល់បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការអាចឱ្យបេឡាជាតិរបបសន្តិសុខសង្គមចុះបញ្ជី និងផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាលជូនពួកគាត់។ ពួកគាត់អាចប្រើប្រាស់ប័ណ្ណនេះ ក្នុងការទៅទទួលសេវាថែទាំសុខភាពផ្សេងៗដោយពុំត្រូវបានកំណត់អំពីប្រភេទបញ្ហាសុខភាពណាមួយដែលត្រូវបានតម្រូវឱ្យបង់ថ្លៃ ឬក៏ប្រភេទ

[៣៥] http://moh.gov.kh

[៣៦] ប្រការ១ នៃប្រកាសអន្តរក្រសួងលេខ៨០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

[៣៧] ប្រការ៤ ដដែល

នៃការព្យាបាលជំងឺណាមួយមិនត្រូវបានទទួលព្យាបាលនោះទេ។ ពួកគាត់គ្រាន់តែបង្ហាញប័ណ្ណមូលនិធិសមធម៌សុខាភិបាល និងអត្តសញ្ញាប័ណ្ណសញ្ជាតិខ្មែររបស់ពួកគាត់ទៅកាន់មន្ត្រី ឬបុគ្គលិកមន្ទីរពេទ្យតែប៉ុណ្ណោះ ដើម្បីឱ្យខាងមន្ទីរពេទ្យកំណត់អត្តសញ្ញាណភាគបានថា ពួកគាត់គឺជាពិតសមាជិកនៃមូលនិធិសមធម៌សុខាភិបាលដោយមិនតម្រូវឱ្យបំពេញទម្រង់បែបបទអ្វីនោះទេ[៣៨]។

ចំពោះការប្រើប្រាស់សេវានេះ ពួកគាត់ត្រូវតែទៅទទួលការថែទាំសុខភាពតាមប្រព័ន្ធផ្តល់សេវាពីថ្នាក់បឋមនៅមូលដ្ឋានសុខាភិបាលថ្នាក់ទាបឡើងជាលំដាប់ឈានទៅកាន់មូលដ្ឋានសុខា-ភិបាលថ្នាក់ខ្ពស់ជាងតាមប្រភេទនៃកម្រិតជំងឺ ដោយមានការចាត់បញ្ជូនអ្នកជំងឺជាដំណាក់ៗ ចាប់ពីកម្រិតថ្នាក់ទី១(មួយ) មណ្ឌលសុខភាព ថ្នាក់ទី២(ពីរ) មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ និងមន្ទីរពេទ្យបង្អែករាជធានី ខេត្ត រហូតដល់ថ្នាក់ទី៣(បី) មន្ទីរពេទ្យជាតិតាមប្រភេទ និងកម្រិតនៃស្ថានភាពអ្នកជំងឺ ប៉ុន្តែត្រលប់មកក្នុងករណីសង្គ្រោះបន្ទាន់ជនរងគ្រោះ ឬអ្នកជំងឺអាចចូលទៅទទួលសេវានៅមូលដ្ឋានសុខាភិបាលសាធារណៈណាដែលនៅជិតបំផុត ដើម្បីធ្វើយ៉ាងណាធានាបាននូវការសង្គ្រោះជីវិតឱ្យរួចផុតពីគ្រោះថ្នាក់ចំពោះមុខជាចំបង[៣៩]។

### ៣.២.២. ប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូន

កម្មការិនី និយោជិតជាស្ត្រីក្រៅប្រព័ន្ធនិងក្នុងប្រព័ន្ធ សមាជិកានៃអង្គការ សមាគមនៃការងារក្រៅប្រព័ន្ធ សមាជិកាភូមិនិងក្រុមប្រឹក្សាឃុំ សង្កាត់ និងកីឡាការិនី គឺសុទ្ធតែទទួលបានប្រាក់ឧបត្ថម្ភបន្ថែមដូចៗគ្នា ពេលពួកគាត់ទៅសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ ឬមន្ទីរពេទ្យឯកជនក៏ដោយ។ ដើម្បីទទួលលបានប្រាក់ឧបត្ថម្ភបន្ថែមពួកគាត់ និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន ឬអ្នកតំណាងស្របច្បាប់របស់ពួកគាត់ត្រូវមានកាតព្វកិច្ចជូនដំណឹងមកបេឡា

[៣៨] កិច្ចសម្ភាសន៍ផ្ទាល់ជាមួយលោកស្រី **ស៊ឹម ស៊ុនណារី** អនុប្រធានការិយាល័យបញ្ជិកា និងភាគទាននៃបេឡាជាតិរបបសន្តិសុខសង្គម កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨

[៣៩] ប្រការ៧ នៃប្រកាសអន្តរក្រសួងលេខ៨០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

ជាតិរបបសន្តិសុខសង្គម អំពីភាពមានគភ៌ក្នុងរយៈពេលយ៉ាងយូរ៣(បី)ខែមុនកាលបរិច្ឆេទនៃការសម្រាលកូនតាមទម្រង់បង់ភាគទាន(E-form) ដែល ប.ស.ស បានកំណត់[៤០]។

ក្នុងករណីខកខានមិនបានជូនដំណឹង តាមពេលកំណត់នេះ សាមីខ្លួន ឬអ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់ក្រោយពេលសម្រាលកូនយ៉ាងយូរបំផុត១(មួយ)ខែ បើពុំនោះសោតនឹងបាត់បង់សិទ្ធិក្នុងការទទួលបានប្រាក់ឧបត្ថម្ភបន្ថែមនេះ[៤១]។

កម្មការិនី និយោជិតជាស្រ្តីទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ សមាជិកានៃអង្គការ សមាគមនៃការងារក្រៅប្រព័ន្ធ សមាជិកាភូមិនិងក្រុមប្រឹក្សាឃុំ សង្កាត់ និងកីឡាការិនី ដែលសម្រាលកូននៅមន្ទីរពេទ្យឬមូលដ្ឋានសុខាភិបាលសាធារណៈ ត្រូវទទួលបានប្រាក់ឧបត្ថម្ភបន្ថែម ដូចខាងក្រោម៖

ក. សម្រាលកូនទោល(មួយ) ទទួលបាន ៤០០,០០០(បួនសែន)រៀល។

ខ. សម្រាលកូនភ្លោះ(ពីរ) ទទួលបាន ៨០០,០០០(ប្រាំបីសែន)រៀល។

គ. សម្រាលកូនភ្លោះ(បី) ទទួលបាន ១,២០០,០០០(មួយលានពីរសែន)រៀល។

ប្រាក់ឧបត្ថម្ភបន្ថែមនេះ ត្រូវផ្តល់ជូនដោយផ្ទាល់ពីបេឡាជាតិរបបសន្តិសុខសង្គម ក្រោយពេលដែលសម្រាលកូនរួច ទោះបីទារករស់ ឬពុំមានភព្វវាសនានឹងរស់រានមានជីវិតក៏ដោយ(ស្លាប់)[៤២]។ ដោយតម្រូវឱ្យពួកគាត់បំពេញទម្រង់លិខិតស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមពីរាជរដ្ឋាភិបាលសម្រាប់កម្មករនិយោជិតជាស្រ្តីពេលសម្រាលកូន ដោយមានការបញ្ជាក់ពីគ្រូពេទ្យ(ឆ្មប)ដែលបានសម្រាល និងការបញ្ជាក់ពីភ្នាក់ងារ(មន្រ្តី) ប.ស.ស នោះខាង ប.ស.ស នឹងគណនា បញ្ជូនទឹកប្រាក់ឧបត្ថម្ភបន្ថែមទៅកាន់ពួកគាត់តាមរយៈធនាគារដៃគូមានធនាគារ អេស៊ីលីដា និងធនាគារឯកទេស

[៤០] សេចក្តីជូនដំណឹងលេខ៣៥/១៧ ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីនីតិវិធីនៃការរាយការណ៍កម្មករនិយោជិតជាស្រ្តីដែលមានគភ៌ដើម្បីទាមទារប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលកម្ពុជាជូនចំពោះកម្មករនិយោជិតជាស្រ្តីនៅពេលសម្រាលកូន សម្រាប់កម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធដែលបានចុះបញ្ជីក្នុងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)

[៤១] ប្រការ១០ នៃប្រកាសអន្តរក្រសួងលេខ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធមិសុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្រ្តីនៅពេលសម្រាលកូន

[៤២] ប្រការ៨ ដដែល

រីង យ៉ាងយូរ១(មួយ)ថ្ងៃ បន្ទាប់ពីការសម្រាលកូន និងទទួលបានទម្រង់លិខិតស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមពីរាជរដ្ឋាភិបាលសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន[៤៣]។

គិតទល់ត្រឹមថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨ កម្មករនិយោជិតជាស្ត្រីដែលបានទៅសម្រាលកូននៅតាមមូលដ្ឋានសុខាភិបាលមានចំនួន១៦,១០១(មួយម៉ឺនប្រាំមួយពាន់មួយរយមួយ)នាក់ និងទារកដែលត្រូវបានសម្រាលមានចំនួន១៦,២១០(មួយម៉ឺនប្រាំមួយពាន់ពីររយដប់)នាក់ សរុបចំនួនទឹកប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាល ដែលត្រូវផ្តល់ជូនដល់ម្តាយរបស់ទារក ជាកម្មការិនីនិយោជិតជាស្ត្រីទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ សមាជិកានៃអង្គការ សមាគមនៃការងារក្រៅប្រព័ន្ធ សមាជិកាភូមិនិងក្រុមប្រឹក្សាឃុំ សង្កាត់ និងកីឡាការិនីមានចំនួន៦,៤៨៤,០០០,០០០(ប្រាំមួយពាន់បួនរយប៉ែតសិបបួនលាន)រៀល[៤៤]។

## ៣.៣. សិទ្ធិទាមទាររបស់កម្មករនិយោជិតក្រៅប្រព័ន្ធក្នុងក្របខ័ណ្ឌ ប.ស.ស

កម្មករនិយោជិតក្រៅប្រព័ន្ធ ពួកគាត់មានសិទ្ធិទាមទារ ក្នុងការទទួលបានអត្ថប្រយោជន៍តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនដែលពួកគាត់បាត់បង់ពីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ក្នុងករណីដែលនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានបង្កើតឱ្យមានភាពធ្វេសប្រហែស និងខកខានមិនបានមកធ្វើការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្រៅប្រព័ន្ធ ដែលកំពុងបម្រើការងារក្នុងសហគ្រាស គ្រឹះស្ថានរបស់ខ្លួន[៤៥]។

ព្រោះថាបានកើតឡើងនូវកិច្ចសន្យាការងារមួយ ទោះផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរក្តី កាលណាប្រើប្រាស់កម្មករនិយោជិត និយោជក ឬម្ចាស់សហគ្រាស់ គ្រឹះស្ថានត្រូវតែទទួលខុសត្រូវលើអ្វីដែលជាគោលនយោបាយរបស់រាជរដ្ឋាភិបាលផ្តល់ជូនដល់កម្មករនិយោជិតក្រៅប្រព័ន្ធនៃសហ-គ្រាស គ្រឹះស្ថានរបស់ខ្លួន។ ក្នុងករណីដែលនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានខកខានមិន

---

[៤៣] កិច្ចសម្ភាសន៍ផ្ទាល់ជាមួយលោក **សុខ បូរ៉ា** ប្រធានការិយាល័យតាវកាលិកនៃបេឡាជាតិរបបសន្តិសុខសង្គម កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨

[៤៤] ដដែល

[៤៥] សេចក្តីជូនដំណឹងលេខ៣៣៦ ក.ប/ស.ជ.ណ.ប.ស.ស ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបានការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិ-បាល និងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន

បានមកចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធ ហើយមិនព្រមទទួលខុសត្រូវទៀត បេឡាជាតិរបបសន្តិសុខសង្គមនឹងចុះទៅអធិការកិច្ចសួរនាំ និងផាក់ពិន័យសហគ្រាស គ្រឹះស្ថានអស់ទាំងនោះក្រោយពីទទួលបានបណ្តឹង ឬការរាយការណ៍អំពីបាតុភាពនោះដោយផ្ទាល់ ឬតាមរយៈខ្សែទូរស័ព្ទពិសេស(hotline):១២៨៦ ដើម្បីអនុញ្ញាឱ្យកម្មករនិយោជិតក្រៅប្រព័ន្ធដែលកំពុងតែបម្រើការងារគ្រប់ទីកន្លែងទាំងអស់ទទួលបានអត្ថប្រយោជន៍នេះ[៤៦]។

ហើយពួកគាត់ក៏អាចប្រែក្លាយពីកម្មករនិយោជិតក្រៅប្រព័ន្ធ ទៅជាសមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គម ដែលហៅថាកម្មករនិយោជិតក្នុងប្រព័ន្ធផងដែរ ពេលណាដែលពួកគាត់បានបម្រើការងារលើសពី៨(ប្រាំបី)ម៉ោងក្នុង១(មួយ)សប្តាហ៍ ធ្វើការងារទៀងទាត់ក្នុងមុខការអ្វីមួយមានលក្ខ-ណៈអចិន្ត្រៃយ៍ក្នុងសហគ្រាស គ្រឹះស្ថានណាមួយ និងគ្រប់លក្ខខណ្ឌអាចចុះបញ្ជីជាកម្មករនិយោជិតក្នុងប្រព័ន្ធ។ ពួកគាត់ទាំងអស់គ្នាមានសិទ្ធិទាមទារឱ្យនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានដែលពួកគាត់កំពុងតែបំពេញការងារឱ្យនោះ ធ្វើការចុះបញ្ជិកាពួកគាត់មកក្នុងប្រព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីពួកគាត់អាចទទួលបានអត្ថប្រយោជន៍ជាតាវកាលិកហានិ-ភ័យការងារ តាវកាលិកថែទាំសុខភាព និងប្រាក់បំណាច់ផ្សេងៗទៀតក្នុងវង្វង់ក្របខ័ណ្ឌបេឡាជាតិរបបសន្តិសុខសង្គមមានលក្ខណៈសម្បូរបែបជាងប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល ដោយទទួលបានត្រឹមការពិនិត្យព្យាបាលឥតគិតថ្លៃប៉ុណ្ណោះ[៤៧]។

បើទោះបីជា សហគ្រាស គ្រឹះស្ថាននោះ ប្រើប្រាស់កម្លាំងកម្មករនិយោជិតត្រឹមម្នាក់ក៏ដោយក៏និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានអាចមកធ្វើការចុះបញ្ជីកម្មករនិយោជិតរបស់ពួកគាត់មកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ជាកម្មករនិយោជិតក្នុងប្រព័ន្ធ(សមាជិក ប.ស.ស)បានដែរ[៤៨]។

---

[៤៦] https://www.youtube.com/watch?v=HrkSY5qifXo

[៤៧] កិច្ចសម្ភាសន៍ផ្ទាល់ជាមួយលោកស្រី **ស៊ឹម ស៊ុនណារី** អនុប្រធានការិយាល័យបញ្ជិកា និងភាគទាននៃបេឡាជាតិរបបសន្តិសុខសង្គម កាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨

[៤៨] ប្រការ១៣ នៃប្រកាសលេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) សម្រាបជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

# សេចក្តីសន្និដ្ឋាន

នៅក្រោមការគិតគូរ និងយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាមកលើប្រជាជនរបស់ខ្លួន តាមរយៈការដាក់ចេញនូវគោលនយោបាយជាតិ និងក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិជាច្រើន។ ឈរលើគោលបំណងជួយសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់សមាជិកសង្គម និងត្រូវបានគាំពារមិនឱ្យធ្លាក់ទៅក្នុងហានិភ័យនៃការបាត់បង់ប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រីក និងពង្រឹងប្រព័ន្ធគាំពារសង្គមឱ្យកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព ទាំងប្រព័ន្ធសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គម។

ជាក់ស្តែង ការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គម ក្នុងដំណាក់កាលចាប់ផ្តើមដំណើរការដំបូងនៃបេឡាជាតិរបបសន្តិសុខសង្គម ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតត្រូវបានអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថានណាដែលមានកម្មករនិយោជិតចំនួនចាប់ពី៨(ប្រាំបី)នាក់ឡើង[៤៩]។ ឈានមកដល់ដំណាក់ចុងក្រោយនេះ ទោះបីជាសហគ្រាស គ្រឹះស្ថាននោះមានប្រើកម្លាំងកម្មករនិយោជិតត្រឹមតែម្នាក់ ក៏ត្រូវបានអនុញ្ញាតឱ្យធ្វើការចុះបញ្ជីដែរ ដោយការិយភារី ឬនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានមានកាតព្វកិច្ចមកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតរបស់ខ្លួន។ បើកម្មករនិយោជិតនោះធ្វើការងារតិចជាង៨(ប្រាំបី)ម៉ោងក្នុង១(មួយ)សប្តាហ៍ គឺត្រូវចុះបញ្ជីគាត់ជាកម្មករនិយោជិតក្រៅប្រព័ន្ធ ប៉ុន្តែបើគាត់បំពេញការងារក្នុងមុខការណាមួយជាប់លាប់(អចិន្ត្រៃយ)ចាប់ពី៨(ប្រាំបី)ម៉ោងក្នុង១(មួយ)សប្តាហ៍ឡើងទៅ ត្រូវចុះបញ្ជីគាត់ជាកម្មករនិយោជិតក្នុងប្រព័ន្ធ។ ដើម្បីឱ្យកម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថាននោះបានទទួលអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម និងពីប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល។ សមាជិកនៃអង្គការសមាគមនានានៃការងារក្រៅប្រព័ន្ធ សមាជិកភូមិនិងក្រុមប្រឹក្សាឃុំ សង្កាត់ និងកីឡាករ កីឡាការិនីអាជីព ពួកគាត់ក៏អាចមកធ្វើការចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម ជាសមាជិករបស់មូលនិធិសមធម៌សុខាភិបាល តាមរយៈតំណាងរបស់ពួកគាត់មកធ្វើការចុះបញ្ជីអង្គការ សមាគម សាលាក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តជាមុនសិន។ ដើម្បីឱ្យសមាជិក សមាជិកានៃអង្គការ សមាគម និងស្ថាប័ន អង្គភាពទាំងអស់នោះទទួលបាននូវការពិនិត្យ

[៤៩] ប្រការ៦ នៃប្រកាសលេខ០២១/០៨ កប-ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)

ព្យាបាលសុខភាពតាមបណ្តាមូលដ្ឋានសុខាភិបាលសាធារណៈដោយឥតបង់កម្រៃសេវា និងទទួលបានប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនសម្រាប់ស្ត្រីជាម្តាយផងដែរ។

សរុបមកការណ៍ទាំងអស់នេះ គឺបានបង្ហាញពីភាពចាំបាច់ក្នុងការជួយទំនុកបម្រុងពួកគាត់លើផ្នែកសុខភាព ដែលជាការរួមចំណែកក្នុងការជួយកាត់បន្ថយការចំណាយ ក្នុងជីវភាពប្រចាំថ្ងៃ និងដោះស្រាយវិបត្តិចំពោះមុខ។ ពេលពួកគាត់ជួបបញ្ហាសុខភាពត្រូវទៅទទួលសេវាថែទាំសុខភាពនៅមន្ទីរពេទ្យបានមួយកម្រិត ដែលធានាដល់សន្តិសុខប្រាក់ចំណូលរបស់កម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធ។ សម្រាប់រាជរដ្ឋាភិបាលវិញ ការដាក់ឱ្យអនុវត្តរបបនេះស្ថិតក្នុងក្របខ័ណ្ឌគាំពារសង្គម ក៏ជាផ្នែកមួយនៃការលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ ព្រោះពេលដែលកម្លាំងជំរុញ ឬផលិតភាពការងាររបស់កម្មករនិយោជិតធ្លាក់ចុះដោយសារជួបប្រទះបញ្ហាសុខភាព។ ពេលណាឈឺហើយខ្វះខាត់ ឬមិនមានលទ្ធភាពទៅទទួលការពិនិត្យ ព្យាបាល នោះសុខភាពរបស់ពួកគាត់រឹតតែដុនដាប យ៉ាប់យឺនដែលមិនអាចទៅបំពេញការងារបន្តទៀតបាន និងបណ្តាលឱ្យបាត់បង់ប្រាក់ចំណូលនាំឱ្យប៉ះពាល់ខ្លាំងក្លាលើជីវភាពគ្រួសារ។ ដោយចំនួនដ៏ច្រើននៃកម្មករនិយោជិត និងបងប្អូននៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធរួមចំណែកកម្លាំងពលកម្មយ៉ាងសម្បើមលើកំណើនសេដ្ឋកិច្ចជាតិ ដូចនេះ បើពួកគាត់ជួបប្រទះបញ្ហាជីវភាពធ្ងន់ធ្ងរហើយ កត្តាអស់នោះនឹងជះឥទ្ធិពលដល់សង្គមជាតិផងដែរ។

# អនុសាសន៍

បេឡាជាតិរបបសន្តិសុខសង្គម ពិតជាមានការរួមចំណែកយ៉ាងសំខាន់ណាស់ ក្នុងការអនុវត្ត ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន សាលាក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងអង្គការ សមាគមនានានៃការងារក្រៅប្រព័ន្ធ រួមនិងកម្មករនិយោជិតទាំងក្នុងនិងក្រៅប្រព័ន្ធ ក៏ដូចជាសមាជិកភូមិនិងក្រុមប្រឹក្សាឃុំ សង្កាត់ កីឡាករ កីឡាការិនីអាជីព សមាជិកនៃអង្គការ សមាគមនានានៃការងារក្រៅប្រព័ន្ធ ដើម្បីផ្តល់ឱកាសឱ្យពួកគាត់បានទទួលនូវអត្ថប្រយោជន៍ដែល រាជរដ្ឋាភិបាលផ្តល់ជូនពួកគាត់។

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវខាងលើ បើទោះបីជាមានការទំនុកបម្រុង និងយកចិត្ត ទុកដាក់ពីរាជរដ្ឋាភិបាលក៏ពិតមែន ប៉ុន្តែក៏ត្រូវការដោយខានមិនបាននូវការចូលរួមសហការពីគ្រប់ មជ្ឈដ្ឋាន និងភាគីពាក់ព័ន្ធ ដូចជាមន្ត្រីអនុវត្ត និយោជក ឬម្ចាស់សហគ្រាស គ្រឹស្ថាន អ្នកដែលជា តំណាងផ្សេងទៀតរបស់បុគ្គលដែលបំពេញការងារក្នុងវិស័យក្រៅប្រព័ន្ធ បងប្អូនសមាជិកភូមិនិង ក្រុមប្រឹក្សាឃុំ សង្កាត និងអ្នកតំណាងកីឡាករ កីឡាការិនីអាជីពផងដែរ។ ដើម្បីសហការពន្លឿន ដំណើរការ និងជំរុញកិច្ចការនៃការចុះបញ្ជិកា ក៏ដូចជាការផ្តល់សេវាសុខាភិបាលតាមមូលដ្ឋានសុ-ខាភិបាលសាធារណៈឱ្យកាន់តែមានភាពប្រសើរឡើង ប្រកបដោយភាពយោគយល់ អធ្យាស្រ័យ សាមគ្គីធម៌ និងសមធម៌ឥតមានអរិភាពក្នុងសង្គមកើតមានឡើងបានគ្រប់រូបភាពទាំងអស់ ទាំងអ្នក ទទួលសេវា និងអ្នកផ្តល់សេវាក្នុងការធានាបាននូវសន្តិសុខប្រាក់ចំណូលជូនបងប្អូននៃការងារវិស័យ ក្រៅប្រព័ន្ធយើង។ ដោយឡែករាជរដ្ឋាភិបាលក៏គួរបង្កើតយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ លើការអនុវត្តរបបគាំពារសង្គមទាំងឡាយ ដែលបានដាក់ចេញ ថាតើមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធផលកម្រិតណា។

ចុងបញ្ចប់នេះ យើងក៏សូមសំណូមពរទៅកាន់រាជរដ្ឋាភិបាលឱ្យនូវតែបន្តការយកចិត្តទុកដាក់ លើកម្មករនិយោជិត បងប្អូននៃការងារវិស័យក្រៅប្រព័ន្ធ កីឡាករ កីឡាការិនីអាជីព និងសមាជិក ភូមិនិងក្រុមប្រឹក្សាឃុំ សង្កាត់បន្តទៀត ហើយឈានដល់ការផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាល និងគិតគូរដល់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងសិស្ស និស្សិត ដែលកំពុងសិក្សានៅតាម បណ្តាភូមិសិក្សា និងឧត្តមសិក្សាផងដែរ ព្រោះថាពួកគាត់ទាំងអស់នោះ ក៏ជាសមាជិកសង្គមដែល ពោពេញទៅដោយសក្តានុពល ហើយគួរតែត្រូវបានគាំពារមិនឱ្យធ្លាក់ទៅក្នុងស្ថានភាពហានិភ័យ សង្គមដោយថាហេតុណាមួយឡើយ។ ការណ៍នេះក៏ជាហេតុញ៉ាំងពួកគាត់កើតមានជំនឿទុកចិត្តមក លើសង្គមជាតិទាំងមូល ដែលជាបច្ច័យនាំទៅដល់ភាពនឹងនរ ធានាស្ថិរភាព និងភាពសុខដុមរមនា

នៅក្នុងសង្គមជាតិ និងរួមចំណែកជួយពន្លឿនដល់ការអនុវត្តគោលនយោបាយជាតិកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលផងដែរ។

# ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧
- ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឆ្នាំ២០០២
- អនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- អនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- អនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា ៧ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- ប្រកាសលេខ០២១/០៨ កប-ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)
- ប្រកាសលេខ១០៨ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ
- ប្រកាសលេខ១០៩ កប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- ប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព
- ប្រកាសអន្តរក្រសួងលេខ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធនិងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន
- ប្រកាសលេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

- សេចក្តីជូនដំណឹងលេខ៣៥/១៧ ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីនីតិវិធីនៃការរាយការណ៍កម្មករនិយោជិតជាស្ត្រីដែលមានគភ៌ដើម្បីទាមទារប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលកម្ពុជាជូនចំពោះកម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនសម្រាប់កម្មករនិយោជិតទាំងក្នុងនិងក្រៅប្រព័ន្ធដែលបានចុះបញ្ជីក្នុងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)
- សេចក្តីជូនដំណឹងលេខ៣៣៦ ក.ប/ស.ជ.ណ.ប.ស.ស ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបានការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន
- ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧
- វេបសាយ ប.ស.ស : www.nssf.gov.kh

# តារាងឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ១ | អនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម |
| ២ | ប្រកាសអន្តរក្រសួងលេខ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន |
| ៣ | ប្រកាសលេខ៤៤៨ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ |
| ៤ | សេចក្តីជូនដំណឹងលេខ៣៥/១៧ ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តពីនីតិវិធីនៃការរាយការណ៍កម្មករនិយោជិតជាស្ត្រីដែលមានគភ៌ដើម្បីទាមទារប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលកម្ពុជាជូនកម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនសម្រាប់កម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធដែលបានចុះបញ្ជីក្នុងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) |
| ៥ | សេចក្តីជូនដំណឹងលេខ៣៣៦ ក.ប/ស.ជ.ណ.ប.ស.ស ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបានការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន |
| ៦ | ទម្រង់បែបបទបង់ភាគទានលេខ «២.០១» នៃប្រកាសលេខ៤៤៩ កប/កប្រ.ក ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ស្តីពីការកំណត់អត្រាបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ |
| ៧ | ទម្រង់លិខិតស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមពីរាជរដ្ឋាភិបាលសម្រាប់កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន |
| ៨ | ខិតប័ណ្ណផ្សព្វផ្សាយព័ត៌មានរបស់បេឡាជាតិរបបសន្តិសុខសង្គម |

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០០៧

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានបេសកកម្មបម្រើសេវាផ្នែកសាធារណៈមានលក្ខណៈសង្គម មានឈ្មោះថា "បេឡាជាតិរបបសន្តិសុខសង្គម" សរសេរជាអក្សរកាត់ "**ប.ស.ស**"។ **ប.ស.ស** ត្រូវស្ថិតនៅក្រោមអាណាព្យាបាល បច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប.ស.ស** មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ។

**មាត្រា ២.-**

**ប.ស.ស** គឺជានីតិបុគ្គលសាធារណៈដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ។

**ប.ស.ស** ត្រូវស្ថិតនៅក្រោមអានុភាពនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ៣.-**

**ប.ស.ស** មានភារកិច្ចដូចខាងក្រោម ÷

១- គ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

២- ធានាផ្តល់ឱ្យបានសមស្របនូវតាវកាលិកទាំងឡាយសម្រាប់សមាជិកនៃ**ប.ស.ស** ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេល ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ មាតុភាព ជាដើម។

៣- ប្រមូលភាគទានពីសមាជិកនៃ**ប.ស.ស** និងនិយោជក ។

៤- សម្របសម្រួល និងរៀបចំឱ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួន។

៥- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បី ÷

-អប់រំផ្សព្វផ្សាយអំពីរបៀបបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ

-ចាត់វិធានការផ្នែកបច្ចេកទេសសន្តិសុខ និង អនាម័យការងារ ។

៦- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវ និងអង្កេតហានិភ័យការងារ ។

៧- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម ។

## ជំពូកទី ២

## រដ្ឋបាលបេឡាជាតិរបបសន្តិសុខសង្គម

### ផ្នែកទី ១

### ក្រុមប្រឹក្សាភិបាល

**មាត្រា ៤.-**

**ប.ស.ស**ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានអំណាចដើម្បីគ្រប់គ្រងគ្រឹះស្ថានក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងក្នុងក្របខ័ណ្ឌនៃបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** ។

ក្រុមប្រឹក្សាភិបាលនេះមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| - តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ (មួយ)រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១ (មួយ)រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល ១( មួយ)រូប | សមាជិក |
| - តំណាងនិយោជក ២(ពីរ) រូប | សមាជិក |
| - តំណាងកម្មករនិយោជិតសមាជិកនៃ **ប.ស.ស** ២(ពីរ)រូប | សមាជិក |
| - នាយកនៃ **ប.ស.ស** | សមាជិកស្វ័យប្រវត្តិ |

**មាត្រា ៥.-**

ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស** មានបេសកកម្មក្នុងការតម្រង់ទិស និងត្រួតពិនិត្យដំណើរប្រព្រឹត្តទៅនៃ **ប.ស.ស**។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលមានភារកិច្ចដូចតទៅ ÷

- អនុម័តថវិកាប្រចាំឆ្នាំរបស់ **ប.ស.ស** ជាពិសេសសម្រាប់គាំពារការលិកនៃផ្នែកសន្តិសុខសង្គមនីមួយៗ ផ្នែករដ្ឋបាល និងផ្នែកសកម្មភាពសុខាភិបាល និងសង្គមកិច្ច

- ពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំស្តីពីការងារគ្រប់គ្រង និងហិរញ្ញវត្ថុនៃ **ប.ស.ស**
- ពិនិត្យ និងសម្រេចលើបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលនៃ **ប.ស.ស**
- ពិនិត្យ និងសម្រេចរចនាសម្ព័ន្ធ និងភារកិច្ចរបស់អង្គភាពចំណុះនៃ **ប.ស.ស**
- កំណត់អំពីបែបបទនៃការជ្រើសរើស ការបញ្ឈប់ពីការងារ ការដំឡើងឋានៈ ឬមុខតំណែង ការដាក់វិន័យ ឬ ការផ្តល់លាភការនៃបុគ្គលិក តាមសំណើរបស់នាយកនៃ **ប.ស.ស**
- សម្រេចចំនួនក្របខ័ណ្ឌនៃបុគ្គលិកដែលអនុញ្ញាតសម្រាប់ **ប.ស.ស**
- ពិនិត្យ និងសម្រេចលើសំណើនៃអត្រាភាគទាននៃផ្នែកសន្តិសុខសង្គមនីមួយៗ
- ពិនិត្យ និងសម្រេចលើសំណើនៃការកំណត់ប្រភេទ និងអត្រាតាវកាលិក
- សម្រេចអំពីកិច្ចសន្យាស្តីពីលទ្ធកម្មនៃ **ប.ស.ស**
- កំណត់កម្មវិធី និងផែនការវិនិយោគនៃ **ប.ស.ស**
- វាយតម្លៃនូវលទ្ធផលការងារនៃ **ប.ស.ស** និងលើកវិធានការកែលម្អការអនុវត្ត
- សហការជាមួយក្រុមប្រឹក្សាបច្ចេកទេសនៃ **ប.ស.ស** សិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមឱ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច ។

**មាត្រា ៦.-**

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រី និងអ្នកដែលសកម្មធ្លាប់បម្រើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងចំណោមឥស្សរជនខ្មែរដែលមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬ សេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ ។

តំណាងនិយោជក និងកម្មករនិយោជិត ត្រូវបានជ្រើសរើសដោយអង្គការវិជ្ជាជីវៈរៀងៗខ្លួន ។ តំណាងទាំងនេះត្រូវមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬ សេដ្ឋកិច្ច ឬ នីតិសាស្ត្រ និង មិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ ។

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣(បី)ឆ្នាំ រៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រសួង ស្ថាប័ន ឬ អង្គការវិជ្ជាជីវៈ ដែលសមាជិកនោះតំណាងឱ្យ ។ អាណត្តិនេះអាចបញ្ចប់ ឬ អាចបន្តទៀតបានតាមសំណើរបស់ ក្រសួង ស្ថាប័ន ឬ អង្គការវិជ្ជាជីវៈ ដែលសមាជិកនោះ តំណាងឱ្យ ។

**មាត្រា ៧.-**

ក្រុមប្រឹក្សាភិបាលត្រូវប្រជុំយ៉ាងតិចមួយដងក្នុងរយៈពេល ៣(បី)ខែ។ ទោះជាមានកំណត់ដូច្នេះក្តី ក្រុមប្រឹក្សាភិបាលអាចប្រជុំបានគ្រប់ពេល អាស្រ័យដោយការចាំបាច់របស់ **ម.ស.ស** តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើរបស់នាយកនៃ**ម.ស.ស** ឬ សមាជិកដែលមានចំនួន ៥ (ប្រាំ)នាក់ យ៉ាងតិចក្នុងចំណោមសមាជិកទាំងអស់។

ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាចំពោះតែបញ្ហាទាំងឡាយដែលមានចុះក្នុងរបៀបវារៈ។ របៀបវារៈនៃអង្គប្រជុំនីមួយៗ ព្រមទាំងឯកសារពាក់ព័ន្ធទាំងអស់ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានយ៉ាងតិចដប់ថ្ងៃប្រតិទិនមុនពេលបើកសម័យប្រជុំ។ នាយកនៃ **ម.ស.ស** ត្រូវចាត់លេខាធិការកត់ត្រានៃអង្គប្រជុំក្រុមប្រឹក្សាភិបាល។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវចូលរួមក្នុង សម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែមិនមានសិទ្ធិបោះឆ្នោត។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ**ម.ស.ស** អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពី ៥០ (ហាសិប) ភាគរយ នៃចំនួនសមាជិកសរុប។ សមាជិក ក្រុមប្រឹក្សាភិបាល ដែលអវត្តមានពុំអាចត្រូវជំនួសបានទេ។ ប្រសិន បើខ្វះកូរ៉ុមការប្រជុំត្រូវលើកទៅ ១៥(ដប់ប្រាំ) ថ្ងៃប្រតិទិនក្រោយ ហើយត្រូវពិភាក្សាឡើងវិញលើរបៀបវារៈដដែល ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអាចយកជា ការបាន លុះណាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នាសំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព។

**មាត្រា ៨.-**

សេចក្តីសម្រេចនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាទុកក្នុងកំណត់ហេតុ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលនៃ **ម.ស.ស** សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក្នុងរវាង ១០(ដប់) ថ្ងៃយ៉ាងយូររាប់គិតពីថ្ងៃចុងក្រោយនៃកិច្ចប្រជុំ។

កំណត់ហេតុនៃកិច្ចប្រជុំត្រូវឆ្លុះបញ្ចាំងភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ ហើយត្រូវចម្លងចូលបញ្ជី ដែលមានលេខរៀងទំព័រតាមលំដាប់លំដោយ និងមានលេខកូដសំគាល់ត្រឹមត្រូវ។ កំណត់ហេតុនេះត្រូវមានចុះហត្ថលេខាប្រធាន និងលេខាធិការអង្គប្រជុំ។ ក្នុងករណីមានការជំទាស់លើកឡើងដោយសមាជិកណាម្នាក់សម្រាប់ការប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាភិបាល ត្រូវមានកត់ត្រាការជំទាស់ទាំងអស់នោះ ក្នុងកំណត់ហេតុនៃកាប្រជុំចុងក្រោយនេះផង។

មាត្រា ៩.-

លាភការនៃមុខងាររបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

មាត្រា ១០.-

សមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីដូចខាងក្រោម ÷

- សមាជិករូបនោះទទួលមរណភាព ឬសុំលាលែង
- សមាជិករូបនោះវិកលចរិត ឬ មានស្មារតីមិនប្រក្រតីដោយមានការបញ្ជាក់ពីក្រសួងសុខាភិបាល
- សមាជិករូបនោះក្ស័យធន
- សមាជិករូបនោះបានទទួលអត្ថប្រយោជន៍ពីកិច្ចសន្យាណាមួយជាមួយ**ប.ស.ស** ឬ បម្រើសេវាកម្មណាមួយឱ្យ **ប.ស.ស** ទោះដោយចំពោះ ឬមិនចំពោះក្តី
- សមាជិករូបនោះត្រូវបានតុលាការផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ
- សមាជិករូបនោះខកខានមិនបានបង់ភាគទានដែលខ្លួនទទួលបន្ទុក
- សមាជិករូបនោះ ដែលបានជាប់ ជាសមាជិកសភា ឬសមាជិករាជរដ្ឋាភិបាល ។

សមាជិកក្រុមប្រឹក្សាភិបាលរូបណាដែលត្រូវបានតុលាការចោទប្រកាន់ ត្រូវព្យួរការងារជាបណ្តោះអាសន្ន ។

ការជំនួសសមាជិកក្រុមប្រឹក្សាភិបាលដែលបាត់បង់សមាជិកភាពរបស់ខ្លួនត្រូវអនុវត្តដូចគ្នាតាមនីតិវិធីនៃការតែងតាំងដែរ ។

## ផ្នែកទី ២
## អង្គការប្រតិបត្តិនៃ ប.ស.ស

មាត្រា ១១.-

នាយកនៃ **ប.ស.ស** ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

នាយកនៃ**ប.ស.ស** មានភារកិច្ចចាត់ចែង គ្រប់គ្រងការងារប្រចាំថ្ងៃរបស់**ប.ស.ស** ។

មាត្រា ១២.-

នាយកនៃ**ប.ស.ស**ត្រូវបានទទួលអំណាចចាំបាច់សម្រាប់ដំណើរការប្រចាំថ្ងៃដើម្បីមានលទ្ធភាពពេញលេញក្នុងការដឹកនាំគ្រឹះស្ថានស្របតាមច្បាប់ និងជាតំណាងនៃ**ប.ស.ស**ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់។ អំណាចនេះត្រូវបានប្រគល់ឱ្យតាមរយៈបទបញ្ជាផ្ទៃក្នុងរបស់**ប.ស.ស** និងតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស**។

ក្នុងក្របខ័ណ្ឌនៃអំណាចនេះ នាយកនៃ**ប.ស.ស** មានភារកិច្ចសំខាន់ៗដូចតទៅ ៖

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**
- រៀបចំឯកសារដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលសម្រេច
- ចាត់ចែងអនុវត្តគ្រប់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងរាយការណ៍តាមដំណាក់កាលនីមួយៗជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាព និងលទ្ធផលការងាររបស់ **ប.ស.ស**
- ទទួលបន្ទុកដឹកនាំ **ប.ស.ស** ផ្នែករដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុ
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ **ប.ស.ស** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និង សម្រេច
- គ្រប់គ្រងបណ្ដាភ្នាក់ងារ ឬ មន្ត្រីគ្រប់រូបរបស់ **ប.ស.ស** ដោយគោរពតាម លក្ខន្តិកៈ ឬ ច្បាប់ជាធរមាន និង តាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- លើកសំណើជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានៈ ដាក់វិន័យ ឬ ផ្ដល់លាភការដល់បុគ្គលិករបស់ **ប.ស.ស** ដែលនៅក្រៅក្របខ័ណ្ឌនៃមន្ត្រីរាជការ ស៊ីវិល
- លើកសំណើជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈពិនិត្យ និងសម្រេច ចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានៈ ដាក់វិន័យ ឬផ្ដល់លាភការដល់មន្ត្រីរាជការ នៃ **ប.ស.ស** ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃ មន្ត្រីរាជការស៊ីវិល
- ធ្វើជាតំណាងនៃ **ប.ស.ស**ចំពោះការតវ៉ា ឬការប្ដឹងជំទាស់នានាទាក់ទងដល់ប្រតិបត្តិការរបស់ **ប.ស.ស** និង ទទួលខុសត្រូវចំពោះមុខច្បាប់លើគ្រប់កិច្ចការពារផលប្រយោជន៍របស់ **ប.ស.ស**។

នាយកនៃ **ប.ស.ស** មានសិទ្ធិផ្ទេរអំណាចខ្លះ ឬ ទាំងអស់រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ឬ កំណត់ដោយក្រុមប្រឹក្សាភិបាល។

**មាត្រា ១៣.-**

គណនេយ្យករនៃ **ប.ស.ស** ត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការឯកភាពគ្នាជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ គណនេយ្យករនេះ ត្រូវស្ថិតនៅក្រោមឱវាទផ្ទាល់របស់នាយកនៃ **ប.ស.ស**។

**មាត្រា ១៤.-**

ការត្រួតពិនិត្យនូវការអនុវត្តបទប្បញ្ញត្តិនៃ "ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ" នៅតាមសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើដោយអធិការឬអភិបាលរបបសន្តិសុខសង្គម និងក្នុងករណីចាំបាច់ត្រូវសហការជាមួយអធិការការងារ ឬអភិបាលការងារ និងអង្គភាពពាក់ព័ន្ធដទៃទៀត។

ការតែងតាំង ការកំណត់តួនាទីភារកិច្ចរបស់អធិការ ឬអភិបាលរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស**។

**មាត្រា ១៥.-**

បុគ្គលិកអចិន្ត្រៃយ៍របស់**ប.ស.ស**រួមមានមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រសួងនានា ឬ មន្ត្រីដែលជ្រើសរើសតាមសំណើរបស់នាយកនៃ **ប.ស.ស**។ មន្ត្រីទាំងនេះ ត្រូវបានទទួលបន្តនូវប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។

បេឡាជាតិរបបសន្តិសុខសង្គមអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងកម្មករ។ បុគ្គលិកទាំងនេះ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ស្តីពីការងារ។

បុគ្គលិកនៃ **ប.ស.ស**ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង។

**មាត្រា ១៦.-**

របនាសម្ព័ន្ធគ្រប់គ្រងនៃ**ប.ស.ស**ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស**។

# ជំពូកទី ៣
# ការគ្រប់គ្រងហិរញ្ញវត្ថុ
## ផ្នែកទី ១
## កិច្ចការគណនេយ្យ

**មាត្រា ១៧.-**

**ម.ស.ស** កាន់កាប់គណនេយ្យស្របតាមគោលការណ៍គណនេយ្យសាធារណៈ និងតាមវិធានគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំដដែល ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាលមុនថ្ងៃទី៣១ ខែមីនា នៃការិយបរិច្ឆេទបន្ទាប់ ។

របាយការណ៍ហិរញ្ញវត្ថុត្រូវសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៨.-**

**១៨.១-** នាយកនៃ **ម.ស.ស** ជាអាណាប័កដើមខ្សែរបស់គ្រឹះស្ថាន ដែលត្រូវមានភារកិច្ច ÷

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ ។

អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវរដ្ឋទេយ្យចំណូល ឬបុរេប្រទានបាន ដោយមានការយល់ព្រមពីគណនេយ្យករ ។

**១៨.២-** ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់**ម.ស.ស** ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ ។ គណនេយ្យករនេះ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ ។ គណនេយ្យករនេះ ត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នក ពិគ្រោះយោបល់ តែឥតមានសំឡេងឆ្នោតឡើយ ។

**១៨.៣-** គណនេយ្យករមានភារកិច្ច ÷

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ

- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់ **ប.ស.ស**
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ ។

**១៨.៤-** គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុការីរបស់ខ្លួន ។

**មាត្រា ១៩.-**

នៅរៀងរាល់ឆ្នាំយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្រុមប្រឹក្សាភិបាលត្រូវផ្ដល់ការយល់ព្រមលើកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំរបស់**ប.ស.ស**តាមសំណើរបស់នាយកនៃគ្រឹះស្ថាននេះ ។ កម្មវិធី និងគម្រោងទាំងនេះត្រូវបញ្ជូនទៅសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២

## ប្រភពធនធាន

**មាត្រា ២០.-**

ប្រភពធនធាននៃ **ប.ស.ស** មានដូចខាងក្រោម ÷

១- ធនធានដំបូងដែលរដ្ឋផ្ដល់សម្រាប់ការបង្កើត **ប.ស.ស** ។

២- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈដែលមានចែងក្នុងថវិការដ្ឋដូចជាឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ។

៣- ភាគទានរបស់សមាជិកនៃ **ប.ស.ស** និង និយោជក ដែលទុកសម្រាប់ហិរញ្ញប្បទានលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ។

៤- ប្រាក់ពិន័យពីការយឺតយូរក្នុងការបង់ភាគទាន ឬការផ្ដល់តារាងបៀវត្ស ព្រមទាំងការប្រាក់ពីការយឺតយូរនេះ ។

៥- ផលចំណេញដែលបានមកពីការវិនិយោគ ។

៦- អំណោយ និងអច្ច័យទានផ្សេងៗ ។

៧- ប្រភពធនធានដទៃទៀតដែល **ប.ស.ស** អាចទទួលបានស្របតាមច្បាប់ ។

## ផ្នែកទី ៣
## ការចំណាយ

**មាត្រា ២១.-**

ការចំណាយរបស់**ប.ស.ស** រួមមាន ÷

១- ការចំណាយសម្រាប់តាវកាលិកនៃផ្នែកនីមួយៗ ។

២- ការចំណាយសម្រាប់ការងាររដ្ឋបាលនៃ **ប.ស.ស** ។

៣- ការចំណាយសម្រាប់សកម្មភាពខាងសុខាភិបាល និងសង្គមកិច្ច ។

៤- ការចំណាយលើការវិនិយោគដើម្បីជាប្រយោជន៍របស់ **ប.ស.ស** ។

ទម្រង់ និងបែបបទនៃការចំណាយខាងលើ ត្រូវចែងលំអិតក្នុងប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

## ផ្នែកទី ៤
## ប្រាក់ត្រៀមបម្រុង

**មាត្រា ២២.-**

ប្រាក់ត្រៀមបម្រុងអប្បបរមាសម្រាប់ផ្នែកហានិភ័យការងារត្រូវស្មើនឹងចំនួនទឹកប្រាក់ចំណាយសម្រាប់ធនលាភដែលបានឧបត្ថម្ភកន្លងទៅ និង ១/២( មួយភាគពីរ) នៃប្រាក់ចំណាយសម្រាប់តាវកាលិកដទៃក្រៅពីធនលាភក្នុងអំឡុងពេល ២( ពីរ) ឆ្នាំចុងក្រោយ ។

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកប្រាក់សោធន និងផ្នែកសន្តិសុខសង្គមផ្សេងៗទៀត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបន្ទាប់ពីបានទទួលសំណើ ពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

អត្រាភាគទានដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះ ត្រូវពិនិត្យឡើងវិញក្នុងករណីដែលប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកនីមួយៗធ្លាក់ចុះទាបជាងកម្រិតអប្បបរមា បន្ទាប់ពីបានទទួលយោបល់ពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកនីមួយៗ ការវិនិយោគប្រាក់នេះ និងផលចំណេញដែលបានមកពីការវិនិយោគត្រូវចុះបញ្ជីគណនេយ្យដាច់ដោយឡែកពីគ្នា ។

## ផ្នែកទី ៥
## មូលនិធិបម្រុង

**មាត្រា ២៣.-**

ត្រូវបង្កើតឱ្យមានមូលនិធិបម្រុងមួយសម្រាប់ការចំណាយនៃផ្នែកទាំងឡាយរបស់របបសន្តិសុខសង្គម ។ មូលនិធិនេះមិនត្រូវតិចជាង២(ពីរ) ដងនៃប្រាក់ចំណាយជាមធ្យមប្រចាំខែរបស់ **ប.ស.ស** នៅក្នុងអំឡុងឆ្នាំចុងក្រោយឡើយ ។

## ផ្នែកទី ៦
## ការវិភាគសន្តិសុខសង្គម

**មាត្រា ២៤.-**

**ប.ស.ស** ត្រូវធ្វើវិភាគហិរញ្ញវត្ថុសម្រាប់របបសន្តិសុខសង្គមយ៉ាងយូរបីឆ្នាំម្តង ។ ក្នុងករណីដែលការវិភាគនេះបង្ហាញថាអាចមានគ្រោះថ្នាក់ដោយសារមានអតុល្យភាពហិរញ្ញវត្ថុនៅក្នុងផ្នែកណាមួយ **ប.ស.ស** ត្រូវស្នើសុំធ្វើការកែតម្រូវអត្រាភាគទាន ឬអាយុចូលនិវត្តន៍ ដើម្បីអាចធានាបាននូវនិរន្តរភាពក្នុងកិច្ចដំណើរការរបស់ **ប.ស.ស** ។

រដ្ឋត្រូវផ្តល់ការឧបត្ថម្ភទ្រទ្រង់ឱ្យ **ប.ស.ស** បន្តនិរន្តរភាពនៅពេលជួបប្រទះឱនភាពថវិកា ។

# ជំពូកទី ៤
# ភាគទាន និងតារាងសន្តិសុខសង្គម

## ផ្នែកទី ១
## ភាគទាន

**មាត្រា ២៥.-**

អត្រានៃភាគទានសម្រាប់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

## ផ្នែកទី ២
## តាវកាលិក

**មាត្រា ២៦.-**

អត្រានៃតាវកាលិកសម្រាប់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**។

ទម្រង់នៃការស្នើសុំតាវកាលិកទាំងអស់ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស**។

## ជំពូកទី ៥
## អាណាព្យាបាល

## ផ្នែកទី ១
## អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៧.-**

**២៧.១**- ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ នាយកនៃ**ប.ស.ស**ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ត្រូវរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសមានរយៈពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារដែលបញ្ជូនដោយនាយកនៃ **ប.ស.ស** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

**២៧.២** -លិខិតយល់ព្រមរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្ញើជូនទៅនាយកនៃ **ប.ស.ស** ដោយមានចម្លងជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។នាយកនៃ**ប.ស.ស** ត្រូវបញ្ជូនព័ត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជំទាស់លើកម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយដោះស្រាយការជំទាស់នេះ ។

កម្មវិធីអភិវឌ្ឍនៃប.ស.ស និងថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលមានការជំទាស់លើកឡើងដោយប្រធានស្ថាប័នអាណាព្យាបាលបច្ចេកទេស ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមលំនាំបំបែកជា១២(ដប់ពីរ) ប៉ុណ្ណោះនៅពេលដែលមានការជំទាស់ពីប្រធានស្ថាប័នអាណាព្យាបាលបច្ចេកទេស ។ ទោះជាយ៉ាងនេះក្តី ថវិកាចំណាយសម្រាប់តាវកាលិកដែលត្រូវផ្តល់ឱ្យកម្មករនិយោជិតត្រូវដាក់ឱ្យអនុវត្តបាន ។

**មាត្រា ២៨.-**

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចមានយោបល់ជំទាស់លើឯកសារ ដែលត្រូវបានបញ្ជូនមកខ្លួនរួមមាន កម្មវិធីអភិវឌ្ឍ គម្រោងថវិកាប្រចាំឆ្នាំ និងកំណត់ហេតុនៃការប្រជុំក្រុមប្រឹក្សាភិបាល ។ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានរយៈពេល១(មួយ)ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងនោះ ។

នាយកនៃប.ស.សត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាលនូវខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំយកជាបានការនូវការជំទាស់ទាំងនោះ សេចក្តីសម្រេចនេះត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជូនដំណឹងជាបន្ទាន់ភ្លាម ស្តីពីបញ្ហានេះជាលាយលក្ខណ៍អក្សរដល់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ២៩.-**

**២៩.១-** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអាចលុប ឬផ្អាកទុកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ **ប.ស.ស** ក្នុងករណីដែលសេចក្តីសម្រេចនោះ ÷

- ផ្ទុយនឹងគោលដៅរបស់ **ប.ស.ស**
- ផ្ទុយនឹងច្បាប់ និងបទបញ្ជា
- ផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ៧ ។

**២៩.២-** ការលុបចោល ឬការផ្អាកនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុប

ចោល ឬការផ្អាកសេចក្តីសម្រេចនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយក **ប.ស.ស**។ នាយកនៃ **ប.ស.ស** ត្រូវជូនព័ត៌មាននេះបន្តទៅក្រុមប្រឹក្សាភិបាល **ប.ស.ស** ក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា ៣០.-**

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចចាត់ឱ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងារក្នុង **ប.ស.ស** ក្នុងករណីដែលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី ២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ៣១.-**

**៣១.១-** ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ **ប.ស.ស** ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានរយៈពេល១(មួយ)ខែ គិតចាប់ពីថ្ងៃដែលទទួលឯកសារដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានរយៈពេល ២ (ពីរ)ខែ គិតចាប់ពីថ្ងៃដែលទទួលបានឯកសារដែលបញ្ជូនមកដោយនាយកនៃ**ប.ស.ស**ដើម្បីសម្រេចផ្តល់ ការយល់ព្រមលើឯកសារនេះ។

**៣១.២-** លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអ្នកតំណាងត្រូវផ្ញើទៅនាយកនៃ **ប.ស.ស** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នាយកនៃ **ប.ស.ស** ត្រូវជូនព័ត៌មាននេះទៅក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ខាងលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវចាត់ទុកថាបានទទួលការឯកភាព។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុតដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនអាចត្រូវបានសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំទាន់ត្រូវបានដោះស្រាយនៅឡើយនោះ។

### មាត្រា ៣២.-

សេចក្តីសម្រេចដូចរៀបរាប់ខាងក្រោមនេះរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ**ម.ស.ស**ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ÷

- សេចក្តីសម្រេចស្តីពីការលក់ ឬផ្ទេរសិទ្ធិអចលទ្រព្យ
- សេចក្តីសម្រេចស្តីពីការលើកលែងគណនេយ្យដែលមានទឹកប្រាក់លើសពីការកំណត់របស់ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានា ឬ លិខិតស្រដៀងគ្នានេះ ។

### មាត្រា ៣៣.-

ត្រូវដាក់ឱ្យនៅអម**ម.ស.ស**នូវមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូប ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនេះ មានភារកិច្ចដូចមានចែងនៅក្នុងអនុក្រឹត្យលេខ ៨១អនក្រ-បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុ លើចំណាយថវិកាតាមក្រសួងអង្គភាពមូលដ្ឋាន តាមបណ្តាខេត្ត ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែលើ **ម.ស.ស** ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្តាលនៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬការត្រួតពិនិត្យលើ **ម.ស.ស** នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី ៦
## បទប្បញ្ញត្តិផ្សេងៗ

### មាត្រា ៣៤.-

**៣៤.១**- សិទ្ធិនានារបស់សមាជិកនៃ **ម.ស.ស** ដែលត្រូវទទួលបាន"តាវកាលិកឧត្តរជីវី" ត្រូវកំណត់ដូចខាងក្រោម ÷

ក-ប្តី ឬ ប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានមុនពេលមានគ្រោះថ្នាក់ការងារ ឬមុនពេលទទួលមរណភាពដោយគ្រោះថ្នាក់ការងារនៃប្តីឬប្រពន្ធ ដែលជាសមាជិកនៃ **ប.ស.ស**។

ខ-កូនដែលមានអាយុត្រឹម ១៨ (ដប់ប្រាំបី) ឆ្នាំចុះ ដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និងមានស្ថានភាព ដូចខាងក្រោម ÷

- កូននៃសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវ។ ក្នុងករណីមានការលែងលះ ឬ ករណីមរណភាពនៃប្តីឬប្រពន្ធ កូននៃអាពាហ៍ពិពាហ៍ក្រោយក៏មានសិទ្ធិ ដូចកូននៃអាពាហ៍ពិពាហ៍ទី១ដែរ
- កូនចិញ្ចឹមរបស់សមាជិកនៃ **ប.ស.ស**។ ស្ថានភាពរបស់កូនចិញ្ចឹមត្រូវកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អាយុកូននៅក្នុងបន្ទុកអាចកំណត់ដល់ ២១(ម្ភៃមួយ) ឆ្នាំ ចំពោះកូនដែលកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ កូនកំពុងរៀននៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ឬ ឯកជនដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច និង មានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ និងកូនពិការ ឬ មានជំងឺរ៉ាំរ៉ៃមិនមានលទ្ធភាពធ្វើការងារដែលមានប្រាក់ឈ្នួល។

គ- ឪពុកម្តាយ ឬ មនុស្សចាស់ជរាដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់សមាជិកនៃ**ប.ស.ស**។

**៣៤.២**- សិទ្ធិវន្តរបស់សមាជិកនៃ**ប.ស.ស**ដែលត្រូវទទួលបាន "គាវកាលិកចំពោះអ្នកនៅក្នុងបន្ទុក" ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីការរៀបចំគាវកាលិកផ្នែកប្រាក់សោធន។

**៣៤.៣**- សិទ្ធិធនលាភចំពោះឧត្តរជីវី និងសោធនចំពោះអ្នកនៅក្នុងបន្ទុករបស់សហព័ទ្ធត្រូវផុតរលត់ ក្នុងករណីដែលសហព័ទ្ធនោះរៀបអាពាហ៍ពិពាហ៍ជាថ្មី។

**មាត្រា ៣៥.-**

**ប.ស.ស** មានបុព្វសិទ្ធិនៃអំណាចសាធារណៈក្នុងការប្រមូលចំណូល ការឱ្យសងបំណុល និងការការពារទ្រព្យសម្បត្តិ ។ បុព្វសិទ្ធិនេះអាចអនុវត្តនៅពេល ដែលសហគ្រាស គ្រឹះស្ថានក្ស័យធន ឬ ត្រូវបានជម្រះបញ្ជីដោយតុលាការ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសាលក្រមរបស់តុលាការ។ នីតិវិធីនៃការទារបំណុលរបស់**ប.ស.ស** ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ភ្នាក់ងារមានសមត្ថកិច្ចតាមច្រក ត្រូវហាមឃាត់មិនឱ្យចាកចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះជនណា ដែលមិនទាន់បានសងបំណុលប.ស.ស តាមដីការបស់តុលាការ ។

**មាត្រា ៣៦.-**

មូលនិធិរបស់ប.ស.ស ត្រូវដាក់ចូលក្នុងគណនី នៅរតនាគារជាតិ ឬនៅធនាគារជាតិនៃកម្ពុជា ឬ នៅធនាគារពាណិជ្ជកម្មផ្សេងៗ ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលនៃប.ស.ស អាចសម្រេចឱ្យប្រើប្រាស់នូវប្រាក់ដែលលើស( ប្រាក់ដែលសល់ពីប្រាក់ត្រៀមបម្រុង) សម្រាប់ការវិនិយោគ បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៣៧.-**

រដ្ឋធានាចំពោះតែបំណុលរបស់ប.ស.ស ណា ដែលមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៣៨.-**

ដំណាក់កាល វិសាលភាព នីតិវិធី និងកាលបរិច្ឆេទដាក់លាក់សម្រាប់ការអនុវត្តផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៩.-**

ក្រោយអនុក្រឹត្យនេះចូលជាធរមាន នាយកដ្ឋានសន្តិសុខសង្គមនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផ្ទេរទៅជាបេឡាជាតិរបបសន្តិសុខសង្គម ។ ប្រធាននាយកដ្ឋានសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវទទួលតួនាទីជានាយកនៃបេឡាជាតិរបបសន្តិសុខសង្គម រហូតមានការតែងតាំងនាយកប.ស.ស ថ្មី។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៤០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៤១

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ:**......៤០៤......**ក.ប**/ប្រ.ក.ប.ស.ស

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ក្រសួងសុខាភិបាល**

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម សម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ/បកចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ/បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមភាពចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសអន្តរក្រសួងនេះ មានគោលបំណងកំណត់ការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនជូនកម្មករនិយោជិតជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ។

**ប្រការ ២.-**

ប្រកាសអន្តរក្រសួងនេះ មានគោលដៅកំណត់អំពីយន្តការគ្រប់គ្រង និងការផ្តល់តាវកាលិករបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនជូនកម្មករនិយោជិតជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ។

**ប្រការ ៣.-**

ប្រកាសអន្តរក្រសួងនេះ មានវិសាលភាពអនុវត្តចំពោះកម្មករនិយោជិតក្រៅប្រព័ន្ធ និងកម្មករនិយោជិតជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ ។

**ប្រការ ៤.-**

វាក្យស័ព្ទបច្ចេកទេសដែលប្រើនៅក្នុងប្រកាសអន្តរក្រសួងនេះ មាននិយមន័យដូចខាងក្រោម៖

- កម្មករនិយោជិតក្រៅប្រព័ន្ធ សំដៅដល់កម្មករនិយោជិតដែលចុះកិច្ចសន្យាធ្វើការងារមួយ ដែលមានរយៈពេលមួយ មិនលើសពី ៨ ម៉ោង ក្នុងមួយសប្តាហ៍ ធ្វើការងារមួយពេលៗ ធ្វើឈប់ៗ ឬធ្វើការងារមួយរដូវៗ ហើយដែលបានចុះបញ្ជីក្នុង ប.ស.ស
- គាំរកាលិកថែទាំសុខភាពផ្នែកមូលនិធិសមធម៌សុខាភិបាល សំដៅដល់សេវាព្យាបាល និងថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល
- មូលនិធិសមធម៌សុខាភិបាលសំដៅដល់យន្តការហិរញ្ញប្បទានផ្នែកគាំពារសុខភាពសង្គមដើម្បីផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋជាក្រុមគោលដៅមួយចំនួនទទួលបាន ឬប្រើប្រាស់សេវាថែទាំសុខភាព ដោយឥតបង់ថ្លៃនៅមូលដ្ឋានសុខាភិបាលសាធារណៈ ដែលរាជរដ្ឋាភិបាលជាអ្នកទទួលបន្ទុកបង់ថ្លៃជំនួស
- កម្មករជាប់លាប់ សំដៅដល់ជនដែលធ្វើការទៀងទាត់ក្នុងមុខការអ្វីមួយ និងដែលមានលក្ខណៈ ជាអចិន្ត្រៃយ៍ ហើយដែលទទួលបានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមប្រព័ន្ធបង់ភាគទាន ដែលជាកាតព្វកិច្ចរបស់និយោជក
- ការសម្រាលកូន សំដៅដល់ការឲ្យកំណើតទារកដែលមានអាយុចាប់ពី ២៦(ម្ភៃប្រាំមួយ) សប្តាហ៍ឡើង នៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ
- ការិយការី សំដៅដល់អ្នកមៅការដែលទទួលការងារពីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលជ្រើសរើសកម្មករហត្ថពលិកដោយខ្លួនឯងតាមត្រូវការដើម្បីប្រតិបត្តិការងារ ឬផ្តល់សេវាណា មួយដោយគិតថ្លៃសរុប។

## ជំពូកទី ២
## ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី

**ប្រការ ៥.-**

បេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស**) ត្រូវទទួលបន្ទុកគ្រប់គ្រង និងចុះបញ្ជីកម្មករ-និយោជិតក្រៅប្រព័ន្ធ និងបើកប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនសម្រាប់កម្មករនិយោជិតជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ។

## ជំពូកទី ៣
## គាំរកាលិកថែទាំសុខភាព និងប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូន
### ផ្នែកទី ១
### គាំរកាលិកថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល

**ប្រការ ៦.-**

គាំរកាលិកថែទាំសុខភាព នៃប្រកាសអន្តរក្រសួងនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ ៧.-**

កម្មករនិយោជិតក្រៅប្រព័ន្ធត្រូវប្រើប្រាស់សេវាតាមប្រព័ន្ធផ្តល់សេវាពីថ្នាក់បឋមនៅមូលដ្ឋានសុខាភិបាលថ្នាក់ទាបទៅមូលដ្ឋានសុខាភិបាលថ្នាក់ខ្ពស់ជាង។ ក្នុងករណីសង្គ្រោះបន្ទាន់ ជនរងគ្រោះ ឬអ្នកជំងឺ អាចចូលទៅទទួលសេវានៅមូលដ្ឋានសុខាភិបាលសាធារណៈដែលនៅជិតបំផុត។

## ផ្នែកទី ២

## ប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនចំពោះកម្មករនិយោជិតជាស្ត្រី

**ប្រការ ៨.-**

កម្មករនិយោជិតជាស្ត្រីទាំងអស់ ទាំងក្នុងនិងក្រៅប្រព័ន្ធ ដែលសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ ត្រូវទទួលបានប្រាក់ឧបត្ថម្ភ ដូចខាងក្រោម៖

ក. សម្រាលកូនទោល (មួយ) ទទួលបាន ៤០០ ០០០(បួនសែន)រៀល។

ខ. សម្រាលកូនភ្លោះ (ពីរ) ទទួលបាន ៨០០ ០០០(ប្រាំបីសែន)រៀល។

គ. សម្រាលកូនភ្លោះ (បី) ទទួលបាន ១ ២០០ ០០០(មួយលានពីរសែន)រៀល។

ប្រាក់ឧបត្ថម្ភនេះ ត្រូវផ្តល់ជូនដោយផ្ទាល់ពី **ប.ស.ស** ក្រោយពេលសម្រាលកូនទោះបីទារករស់ ឬស្លាប់ក៏ដោយ ។

## ជំពូកទី ៤

## ការចុះបញ្ជី

## ផ្នែកទី ១

## ការចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធ

**ប្រការ ៩.-**

និយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថានទាំងអស់ ត្រូវមានកាតព្វកិច្ចចុះបញ្ជីកម្មករ-និយោជិតរបស់ខ្លួនមកក្នុង **ប.ស.ស** ទោះជាកម្មករនិយោជិតនោះ ជាកម្មករនិយោជិតជាប់លាប់ ឬកម្មករនិយោជិតម្តងម្កាលក៏ដោយ។

**ប្រការ ១០.-**

កម្មករនិយោជិតជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ ឬអ្នកតំណាងស្របច្បាប់ត្រូវជូនដំណឹងមកបេឡាជាតិរបបសន្តិសុខសង្គមអំពីភាពមានគភ៌ក្នុងរយៈពេលយ៉ាងយូរបីខែមុនកាលបរិច្ឆេទនៃការសម្រាលកូន។ ក្នុងករណីខកខានមិនបានជូនដំណឹង តាមពេលកំណត់នេះ សាមីខ្លួនឬអ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់ក្រោយពេលសម្រាលកូនយ៉ាងយូរបំផុត ១ខែ បើពុំនោះសោតនឹងបាត់បង់សិទ្ធិក្នុងការទទួលបានប្រាក់ឧបត្ថម្ភបន្ថែមនេះ។

## ផ្នែកទី ២
## ការចុះបញ្ជីកម្មករនិយោជិត ដែលជ្រើសរើសដោយការិយការី

**ប្រការ ១១.-**

និយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថានទាំងអស់ ដែលប្រើប្រាស់ការិយការី ត្រូវមានកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរជាមួយការិយការី និងត្រូវមានបញ្ជីរាយនាមការិយការី ដែលខ្លួនបានចុះកិច្ចសន្យាជាមួយ។

ការិយការីទាំងអស់ត្រូវមានកាតព្វកិច្ចចុះបញ្ជីកម្មករនិយោជិត ដែលខ្លួនបានប្រើប្រាស់ក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបានការថែទាំសុខភាព និងប្រាក់ឧបត្ថម្ភបន្ថែមនៅពេលសម្រាលកូន។

**ប្រការ ១២.-**

ក្នុងករណីដែលការិយការីខកខានមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងប្រការ ១១ ខាងលើ និយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថាន ដែលបានចុះកិច្ចសន្យាជាមួយការិយការីនោះ ត្រូវតែយកខ្លួនជំនួសការិយការី ដើម្បីបំពេញកាតព្វកិច្ចចុះបញ្ជីកម្មករនិយោជិត ដែលជ្រើសរើសដោយការិយការីនោះ។

## ជំពូកទី ៥
## ប្រភពហិរញ្ញប្បទាន

**ប្រការ ១៣.-**

រាល់ការចំណាយលើការផ្តល់សេវាថែទាំសុខភាពសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូន ត្រូវហិរញ្ញប្បទានដោយថវិការដ្ឋ ។

ឥណទានថវិកានេះត្រូវគ្រោងដាច់ដោយឡែកពី ឥណទានថវិកាមូលនិធិសមធម៌សុខាភិបាលសម្រាប់ប្រជាពលរដ្ឋក្រីក្រ។

## ជំពូកទី ៦
## កាលបរិច្ឆេទនៃការអនុវត្ត

**ប្រការ ១៤.-**

ការផ្តល់តាវកាលិកផ្នែកថែទាំសុខភាពចំពោះកម្មករនិយោជិតក្រៅប្រព័ន្ធ និងប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនចំពោះកម្មករនិយោជិតជាស្ត្រី ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃប្រកាសអន្តរក្រសួងនេះ ត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ១៥.-**

អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

| ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | រដ្ឋមន្ត្រី ក្រសួងសុខាភិបាល | រដ្ឋមន្ត្រី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
|---|---|---|
| បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន | ម៉ម ប៊ុនហេង | អ៊ិត សំហេង |

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ៤៤៨ ក.ប/ប.ក.ប.ស.ស

# ប្រកាស
## ស្តីពី
## បញ្ជីភាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៨៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ .-**

ប្រកាសនេះមានគោលបំណងចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព។

**ប្រការ ២ .-**

ប្រកាសនេះមានគោលដៅកំណត់បែបបទ និងនីតិវិធី នៃការចុះបញ្ជិកាសហគ្រាស គ្រឹះ ស្ថាន និងកម្មករនិយោជិត ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ។

**ប្រការ ៣ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។

**ប្រការ ៤ .-**

វាក្យស័ព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម ៖

- ***សហគ្រាស*** សំដៅដល់សហគ្រាស ឬគ្រឹះស្ថាន ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សេវាកម្ម កសិកម្ម សិប្បកម្ម ដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅសាសនា ឬក្នុងសាសនាក៏ដោយ ទោះមានលក្ខណៈជាបង្រៀនវិជ្ជាជីវៈឬជាការកុសលក៏ដោយ ព្រមទាំងវិជ្ជាជីវៈ សេរីនៃសមាគម ឬក្រុមប្រភេទណាក៏ដោយ ។ សហគ្រាសអាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗ

មានប្រើមនុស្សឱ្យធ្វើការងារក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំរបស់និយោជក ។ គ្រឹះស្ថានស្ថិតនៅក្រោមឱវាទសហគ្រាសមួយជានិច្ច ។ គ្រឹះស្ថានអាចមានប្រើមនុស្សតែម្នាក់ក៏បានដែរ ។ ករណីគ្រឹះស្ថាននេះមានតែមួយឯកឯង និងមិននៅក្រោមសហគ្រាសណាទេ គ្រឹះស្ថាននោះត្រូវចាត់ទុកជាសហគ្រាស ។

- ***និយោជក*** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ជាសាធារណៈ ឬឯកជន ដែលប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះជាកម្មករនិយោជិតជាប់លាប់ ឬម្តងម្កាល ។
- ***កម្មករនិយោជិត*** សំដៅដល់ជនគ្រប់ភេទ និងគ្រប់សញ្ជាតិ ដែលបានចុះកិច្ចសន្យា យកកំរៃជាសាធារណៈ ឬឯកជន ។ លក្ខណៈសម្បត្តិនៃកម្មករនិយោជិត មិនត្រូវគិតពីលក្ខន្តិកៈគតិយុត្តនៃនិយោជក ឬលក្ខន្តិកៈគតិយុត្តនៃកម្មករនិយោជិត ព្រមទាំងមិនត្រូវគិតពីប្រាក់ឈ្នួលតិច ឬច្រើន ។

# ជំពូកទី ២
# ការចុះបញ្ជី
## ផ្នែកទី១
## ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

**ប្រការ ៥ ._**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលនៅក្នុងដែនអនុវត្ត នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានរបស់ខ្លួន នៅបេឡាជាតិរបបសន្តិសុខសង្គម ។

រយៈពេលកំណត់នៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន មានដូចតទៅ ៖

- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលកំពុងដំណើរការ និងមិនទាន់បានចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម រយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីប្រកាសនេះចូលជាធរមាន ។
- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបើកដំណើរការថ្មី ក្រោយពីប្រកាសនេះចូលជាធរមាន ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម រយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាស គ្រឹះស្ថាន ។
- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព រួចហើយ មិនមានកាតព្វកិច្ចក្នុងការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ឡើងវិញទេ ។

**ប្រការ ៦ ._**

ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើតាមទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ឬហៅថាទម្រង់ "១.០១" ដែលមានចែងក្នុងឧបសម្ព័ន្ធ ១ នៃប្រកាសនេះ ។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយទម្រង់ "១.០១" នូវវិញ្ញាបនបត្របញ្ជិកាពាណិជ្ជកម្ម ដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬលិខិតូបករណ៍គតិយុត្តសមមូលដទៃទៀត ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះកម្មករនិយោជិត ក្នុងពេលដំណាលគ្នានិងទម្រង់បញ្ជិកាសហគ្រាស គ្រឹះស្ថាន ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចជូនដំណឹងមក ប.ស.ស ក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ បន្ទាប់ពីមានការព្យួរ បិទ ឬ ផ្អាកសកម្មភាពអាជីវកម្ម ការប្តូរនិយោជក ឬម្ចាស់សហគ្រាស ឬអ្នកតំណាង អាសយដ្ឋាន ឬនាមករណ៍សហគ្រាស ។

## ផ្នែកទី ២
## ការចុះបញ្ជីកម្មករនិយោជិត

**ប្រការ ៧ ._**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចចុះបញ្ជីកម្មករនិយោជិត មកក្នុងបេឡាជាតិរបបសន្តិសុខសង្គម យ៉ាងយូររយៈពេល ៣ (បី) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទអនុញ្ញាតឱ្យចូលធ្វើការ លើកលែងតែកម្មករនិយោជិតដែលមានប័ណ្ណសមាជិក ប.ស.ស រួចហើយ ។

**ប្រការ ៨ ._**

នីតិវិធី និងបែបបទនៃការចុះបញ្ជីកម្មករនិយោជិត មកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ត្រូវធ្វើតាមទម្រង់សលាកប័ត្រព័ត៌មានកម្មករនិយោជិត ឬហៅថាទម្រង់ "១.០២" ដែលមានចែងក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។

ដើម្បីចុះបញ្ជីក្នុង ប.ស.ស កម្មករនិយោជិតសញ្ជាតិខ្មែរត្រូវមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដោយឡែកចំពោះកម្មករនិយោជិតបរទេសត្រូវមានលិខិតឆ្លងដែន ។

## ផ្នែកទី ៣
## អត្តសញ្ញាណកម្មសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

**ប្រការ ៩ ._**

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវផ្តល់លេខអត្តសញ្ញាណសម្រាប់សហគ្រាស គ្រឹះស្ថាន នីមួយៗ បន្ទាប់ពីទទួលបានទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ។ សហគ្រាស គ្រឹះស្ថាន

មួយត្រូវទទួលបានលេខអត្តសញ្ញាណតែមួយគត់ ដែលឱ្យឈ្មោះថា "លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន" ។

បេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្តល់ "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន" ជូនទៅសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិការួច ។ វិញ្ញាបនបត្រនេះចាំបាច់ត្រូវមានចុះលេខ "អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន" និង កាលបរិច្ឆេទចុះបញ្ជិកា ។ និយោជកត្រូវដាក់តាំងវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន នៅនឹងការិយាល័យបើកប្រាក់ឈ្នួលរបស់សហគ្រាស គ្រឹះស្ថាន ។

**ប្រការ ១០ .-**

បន្ទាប់ពីបានទទួលទម្រង់សលាកប័ត្រព័ត៌មានកម្មករនិយោជិត និងការកំណត់អត្តសញ្ញាណកម្មករនិយោជិតរួចហើយបេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្តល់លេខអត្តសញ្ញាណកម្មករនិយោជិត និងចេញប័ណ្ណសមាជិក ប.ស.ស ជូនកម្មករនិយោជិតម្នាក់ៗដោយឥតគិតថ្លៃ ។ ប័ណ្ណសមាជិក ប.ស.ស ត្រូវប្រគល់ជូនកម្មករនិយោជិតតាមរយៈនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ។

ក្នុងករណីដែល "ប័ណ្ណសមាជិក ប.ស.ស" ខូច ឬបាត់បង់ សាមីជនដែលជាម្ចាស់ប័ណ្ណត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងត្រូវស្នើសុំទុតិយតា ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងខាងលើ ។ ការផ្តល់ប័ណ្ណទុតិយតាតម្រូវឱ្យសាមីជនបង់ប្រាក់ចំនួន **២,០០០ (ពីរពាន់) រៀល** ជូនទៅបេឡាជាតិរបបសន្តិសុខសង្គម ។

## ផ្នែកទី ៤
## របាយការណ៍កម្មករនិយោជិត

**ប្រការ ១១ .-**

រៀងរាល់ខែ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទៅបេឡាជាតិរបបសន្តិសុខសង្គម យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ ។

របាយការណ៍អំពីចំនួនកម្មករនិយោជិត ត្រូវបញ្ជាក់អំពីចំនួនកម្មករនិយោជិតទាំងអស់ដែលមាននៅក្នុងខែត្រូវរាយការណ៍ ។ របាយការណ៍អំពីចំនួនកម្មករនិយោជិត ដែលត្រូវផ្តល់ជូនបេឡាជាតិរបបសន្តិសុខសង្គម អាចធ្វើតាម "ទម្រង់ក្រដាស" ឬ "ទម្រង់អេឡិចត្រូនិច" ដោយមានភ្ជាប់លិខិតបញ្ជូន ចុះហត្ថលេខាដោយនិយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ។

## ជំពូកទី ៣
## ទោសប្បញ្ញត្តិ

**ប្រការ ១២ .-**

ជនដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលទោសដូចមានចែងក្នុងជំពូកទី៥ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**ប្រការ ១៣ .-**

ប្រកាសលេខ ០២១/០៨ ក.ប-ប្រ.ក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម ប្រកាសលេខ ២៨៥ ក.ប-ប្រ.ក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ និងប្រការ៥ នៃប្រកាសលេខ ០២១/០៨ ក.ប-ប្រ.ក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៤ .-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

<u>កន្លែងទទួល</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួងពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង "ដើម្បីអនុវត្ត"
- សមាគមនិយោជក និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- គ្រប់សហព័ន្ធសហជីព
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ២. នៃប្រកាសលេខ:..៤៤៨..កប/ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ១.០២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ..............................

## សលាកប័ត្រព័ត៌មាន

## កម្មករនិយោជិត

លេខអត្តសញ្ញាណប.ស.ស

☐☐☐☐☐☐☐ - ☐☐☐☐☐☐☐ - ☐

### ក- ព័ត៌មានផ្ទាល់ខ្លួន

១- គោត្តនាម....................... នាម ................................ ជាអក្សរឡាតាំង ..................................................

២- ភេទ......... សញ្ជាតិ.................... ថ្ងៃខែឆ្នាំកំណើត ....../........./.......... អត្តសញ្ញាណប័ណ្ណលេខ..................................

៣- ទីកន្លែងកំណើត ផ្ទះលេខ............. ផ្លូវ.................. ភូមិ/ក្រុម............................ ឃុំ/សង្កាត់.....................................

ស្រុក/ខណ្ឌ/ក្រុង ........................................ ខេត្ត/រាជធានី ...........................................................................

៤- អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ..............ផ្លូវ .................. ភូមិ/ក្រុម......................... ឃុំ/សង្កាត់...................................

ស្រុក/ខណ្ឌ/ក្រុង ...............................ខេត្ត/រាជធានី ...................................លេខទូរស័ព្ទ:.......................................

### ខ- ព័ត៌មានការងារ

៥- ឈ្មោះសហគ្រាស...........................................................................លេខអត្តសញ្ញាណស.ហ.........................................

៦- លេខអត្តសញ្ញាណ ប.ស.ស ចាស់.......................................................លេខអត្តសញ្ញាណ នៅស.ហ.....................................

៧- មុខងារ ................................................... ប្រាក់ឈ្នួល ........................ កាលបរិច្ឆេទចូលធ្វើការ......../........./..........

### គ- ព័ត៌មានគ្រួសារ

៨- ☐ នៅលីវ ☐ រៀបអាពាហ៍ពិពាហ៍ ☐ មេម៉ាយ/ពោះម៉ាយ

៩- ប្រពន្ធ ឬប្តីឈ្មោះ.................................................... សញ្ជាតិ...................... ថ្ងៃខែឆ្នាំកំណើត......../........./..........

មុខរបរសព្វថ្ងៃ ...........................................................................................................................................

១០-អំពីកូន..........នាក់

១. ឈ្មោះ .................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ ................................

២. ឈ្មោះ .................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ ................................

៣. ឈ្មោះ .................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ ................................

| មេដៃខាងឆ្វេង | មេដៃខាងស្តាំ |
| --- | --- |

ខ្ញុំបាទ/នាងខ្ញុំ សូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានបំពេញខាងលើនេះពិតជាត្រឹមត្រូវប្រាកដមែន ។

ធ្វើនៅ..............ថ្ងៃទី.......ខែ..........ឆ្នាំ២០...

ធ្វើនៅ........... ថ្ងៃទី..........ខែ........... ឆ្នាំ២០...

**ហត្ថលេខា ឬស្នាមម្រាមដៃសាមីខ្លួន**

**ហត្ថលេខា និង ឈ្មោះមន្ត្រីពិនិត្យ**

**ឯកសារភ្ជាប់**
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- លិខិតឆ្លងដែន

ឧបសម្ព័ន្ធ ១. នៃប្រកាសលេខ:...២២៨....ក.ប/ប្រ.ក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ១.០១

# បញ្ជិកាសហគ្រាស គ្រឹះស្ថាន

| សម្រាប់មន្ត្រី ប.ស.ស |
|---|
| លេខអត្តសញ្ញាណសហគ្រាសគ្រឹះស្ថាន: ☐☐☐☐☐☐☐☐ |
| ហត្ថលេខា:...................... / / |

**១.** ឈ្មោះសហគ្រាស គ្រឹះស្ថាន:..........................................

ឈ្មោះជាអក្សរឡាតាំង:..........................................

**២.** អាសយដ្ឋានទីស្នាក់ការកណ្តាល:អគារលេខ..........ផ្លូវ..........ឃុំ/សង្កាត់..........ស្រុក/ខណ្ឌ/ក្រុង..........រាជធានី/ខេត្ត..........

ទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐ ទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:..........

**៣.** អាសយដ្ឋាននៃកន្លែងធ្វើការងារ: អគារលេខ..........ផ្លូវ..........ឃុំ/សង្កាត់..........ស្រុក/ខណ្ឌ/ក្រុង..........រាជធានី/ខេត្ត..........

ទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐ ទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:..........

(ប្រសិនបើអាសយដ្ឋានកន្លែងធ្វើការដូចគ្នាជាមួយនឹងអាសយដ្ឋានទីស្នាក់ការកណ្តាល ចំណុចលេខ ៣ នេះពុំចាំបាច់ត្រូវបំពេញទេ)

**៤.** លេខបញ្ជិកាពាណិជ្ជកម្ម: ☐☐☐☐☐☐☐☐☐☐☐☐☐ ប្រភេទសហគ្រាស គ្រឹះស្ថាន: ☐☐☐☐ **(សម្រាប់មន្ត្រី ប.ស.ស)**

កាលបរិច្ឆេទបើកសហគ្រាស គ្រឹះស្ថាន:........./........./.........កាលបរិច្ឆេទមានកម្មករចាប់ពី ០១នាក់ ឡើង:........./........./.........

**៥.** ឈ្មោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន:..........................ភេទ:..........សញ្ជាតិ:..........

ឈ្មោះជាអក្សរឡាតាំង:..........................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខ:..........................................

អាសយដ្ឋានអចិន្ត្រៃយ៍:អគារលេខ..........ផ្លូវ..........ឃុំ/សង្កាត់..........ស្រុក/ខណ្ឌ/ក្រុង..........រាជធានី/ខេត្ត..........

ទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐ ទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:..........

**៦.** ឈ្មោះអ្នកគ្រប់គ្រង/អ្នកតំណាងនិយោជក:..........................ភេទ:..........សញ្ជាតិ:..........

ឈ្មោះជាអក្សរឡាតាំង:..........................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខ:..........................................

អាសយដ្ឋានអចិន្ត្រៃយ៍:អគារលេខ..........ផ្លូវ..........ឃុំ/សង្កាត់..........ស្រុក/ខណ្ឌ/ក្រុង..........រាជធានី/ខេត្ត..........

ទូរស័ព្ទ: ☐☐☐☐☐☐☐☐☐☐ ទូរសារ: ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:..........

ខ្ញុំសូមសន្យាថា រាល់ព័ត៌មានដែលផ្តល់ជូនខាងលើ ពិតជាត្រឹមត្រូវប្រាកដមែន ។

..................ថ្ងៃទី..........ខែ..........ឆ្នាំ..........

**ហត្ថលេខា និងត្រានាយក**

ឯកសារត្រូវយកភ្ជាប់មកជាមួយ:
- បញ្ជិកាពាណិជ្ជកម្ម
- ប័ណ្ណប៉ាតង់
- របាយការណ៍ប្រើប្រាស់កម្មករនិយោជិត
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់និយោជក និងអ្នកតំណាង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិរបបសន្តិសុខសង្គម**

លេខ : ៧០៥/១៧ ប.ស.ស

*រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧*

# សេចក្តីជូនដំណឹង

## ស្តីពី

## នីតិវិធីនៃការរាយការណ៍កម្មករនិយោជិតជាស្ត្រីដែលមានគភ៌ដើម្បីទាមទារប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលកម្ពុជាជូនកម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន សម្រាប់កម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធដែលបានចុះបញ្ជីក្នុងបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)

<u>**យោង**</u> ៖ - អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

- ប្រកាសអន្តរក្រសួងលេខ៤០៤ ក.ប/ប្រក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

បេឡាជាតិរបបសន្តិសុខសង្គម មានកិត្តិយសសូមជម្រាបជូនដល់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារអោយបានជ្រាបថា៖ ដើម្បីទទួលបាននូវប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវមានកាតព្វកិច្ចជូនដំណឹងមក ប.ស.ស អំពីភាពមានគភ៌ក្នុងរយៈពេលយ៉ាងយូរបីខែមុនកាលបរិច្ឆេទនៃការសម្រាលកូនតាមទម្រង់បង់ភាគទាន(E-form)ដែលប.ស.សបានកំណត់។ ក្នុងករណីខកខានមិនបានជូនដំណឹងតាមពេលកំណត់នេះសាមីខ្លួន ឬអ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់ក្រោយពេលសម្រាលកូនយ៉ាងយូរបំផុតមួយខែមកប.ស.ស បើពុំនោះសោតនឹងបាត់បង់សិទ្ធក្នុងការទទួលបានប្រាក់ឧបត្ថម្ភបន្ថែមនេះ។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងករណីខកខានមិនបានជូនដំណឹងអំពីភាពមានគភ៌របស់កម្មករនិយោជិតមកប.ស.ស ដែលនាំអោយបាត់បង់ប្រាក់ឧបត្ថម្ភបន្ថែមនេះ។

បេឡាជាតិរបបសន្តិសុខសង្គម សង្ឃឹមយ៉ាងមុតមាំថា លោក/លោកស្រី ជានិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតនឹងចូលរួមអនុវត្តតាមខ្លឹមសារនេះជាក់ជាពុំខាន។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកបេឡាជាតិរបបសន្តិសុខសង្គម**

**អ៊ិត សមហ៊ា**

អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ , ០២៣ ៨៨ ១០ ១៥ , ០២៣-៨៨ ១០ ១៦ , ០២៣ ៨៨ ០៤ ១៧
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ...............៣៣៦................ក.ប/ស.ជ.ណ.ប.ស.ស

# សេចក្តីជូនដំណឹង

## ស្តីពី

## ការចុះបញ្ជីកម្មករនិយោជិតក្រៅប្រព័ន្ធមកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបានការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

**យោង៖** -មាត្រា២ នៃច្បាប់ស្តីពីការងារ

-ប្រកាសអន្តរក្រសួងលេខ ៤០៤ ក.ប/ ប្រក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ និយោជក ម្ចាស់ សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារជ្រាបថា ដើម្បីអនុវត្តអនុសាសន៍ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានស្នើឲ្យនិយោជក ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលកំពុងប្រើប្រាស់កម្មករនិយោជិតម្នាក់ ឬច្រើននាក់ ត្រូវមានកាតព្វកិច្ចចុះបញ្ជីសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត មកក្នុងបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបានរបបសន្តិសុខសង្គម ដោយឡែកសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធនឹងទទួលបានការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនទាំងក្នុងនិងក្រៅប្រព័ន្ធ។

អាស្រ័យហេតុនេះ ក្រសួង សូមអញ្ជើញ និយោជក ម្ចាស់ សហគ្រាស គ្រឹះស្ថាន ដែលមិនទាន់បានចុះបញ្ជីនៅ ប.ស.ស សូមរួសរាន់មកចុះបញ្ជីឲ្យបានមុនថ្ងៃអាទិត្យ ១៤ កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី៣១ ខែធ្នូ គ.ស ២០១៧ នៅអគារ ប.ស.ស (ស្នាក់ការកណ្តាល) ក្នុងបរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតាមសាខា ប.ស.ស ខេត្ត/ខណ្ឌ។

ក្នុងករណីខកខាន មិនបានចុះបញ្ជីតាមការកំណត់ខាងលើ និយោជក ម្ចាស់ សហគ្រាស គ្រឹះស្ថាន ត្រូវទទួលខុសត្រូវនៅចំពោះមុខច្បាប់ ពិសេសត្រូវផ្តល់អត្ថប្រយោជន៍ដល់ បុគ្គលិក កម្មករនិយោជិត ដែលខ្លួនកំពុងប្រើប្រាស់(របបសន្តិសុខសង្គម សេវាមូលនិធិសមធម៌សុខាភិបាល និងប្រាក់ឧបត្ថម្ភដល់កម្មករ-និយោជិតជាស្ត្រីនៅពេលសម្រាលកូន)។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា និយោជក ម្ចាស់ សហគ្រាស គ្រឹះស្ថានទាំងអស់ នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ប្រកបដោយស្មារតីទទួលខុសត្រូវ។

ថ្ងៃចន្ទ ១រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ គ.ស ២០១៧

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

ឧបសម្ព័ន្ធ២ប្រកាសលេខ ៤៤៩ កប/ប្រ.កស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

២.០១

**សម្រាប់មន្ត្រីប.ស.ស**
លេខកូដភាគទាន:
ហត្ថលេខា: ........................ / /

# បែបបទបង់ភាគទាន

១.ឈ្មោះសហគ្រាស:.................................................. ២.លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន: | | | | | | | | |

៣.ឈ្មោះសហគ្រាសជាអក្សរឡាតាំង:..................................................

| ភាគទានបង់សម្រាប់ខែ..........ឆ្នាំ.......... | | | | | | | |
|---|---|---|---|---|---|---|---|
| លេខរៀង | លេខអត្តសញ្ញាណកម្មករនិយោជិត | ឈ្មោះកម្មករនិយោជិត | ប្រាក់ឈ្នួលប្រចាំខែ | ប្រាក់ឈ្នួលមធ្យមជាប់ភាគទាន | ភាគទានផ្នែកហានិភ័យការងារ | ភាគទានផ្នែកថែទាំសុខភាព | ភាគទានសរុប |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | សរុប= | | | |

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលផ្តល់ជូនខាងលើពិតជាត្រឹមត្រូវ និងធានាខុសត្រូវលើរាល់កំហុសឆ្គងទាំងអស់។

........................ ថ្ងៃទី ខែ ឆ្នាំ

**ហត្ថលេខា និងត្រានិយោជក**

ទម្រង់ស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលពេលសម្រាលកូន

| សម្រាប់មន្ត្រី ប.ស.ស |
|---|
| ឈ្មោះ:................................................ |
| ..................ថ្ងៃទី.......ខែ..... ឆ្នាំ២០១... |
| ហត្ថលេខា |

# លិខិតស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់ កម្មករនិយោជិតជាស្ត្រីពេលសម្រាលកូន

❶ នាមករណ៍សហគ្រាស......................................................................................................

លេខអត្តសញ្ញាណសហគ្រាស: ☐☐☐☐☐☐☐☐

អាសយដ្ឋានអចិន្ត្រៃយ៍: លេខ...................ផ្លូវ.................សង្កាត់/ឃុំ............................ខណ្ឌ/ស្រុក/ក្រុង..................................រាជធានី/ខេត្ត..................................

លេខទូរស័ព្ទ:......................................................................................................

❷ សមាជិក ☐-កម្មករនិយោជិតក្នុងប្រព័ន្ធ ☐-កម្មករនិយោជិតក្រៅប្រព័ន្ធ

គោត្តនាម និងនាមកម្មករនិយោជិត:......................................................................................................

លេខអត្តសញ្ញាណកម្មករនិយោជិត: ☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐

អាសយដ្ឋានអចិន្ត្រៃយ៍: ផ្ទះលេខ..................ផ្លូវ................សង្កាត់/ឃុំ...........................ខណ្ឌ/ស្រុក/ក្រុង..................................រាជធានី/ខេត្ត..................................

លេខទូរស័ព្ទ:......................................................................................................

❸ ព័ត៌មានសម្រាល

◉បានសម្រាលទារកចំនួន:.................................នាក់

-គោត្តនាម និងនាមកូនទី១.......................................................................ភេទ:........................ ☐-រស់ ☐-ស្លាប់

-គោត្តនាម និងនាមកូនទី២.......................................................................ភេទ:........................ ☐-រស់ ☐-ស្លាប់

-គោត្តនាម និងនាមកូនទី៣.......................................................................ភេទ:........................ ☐-រស់ ☐-ស្លាប់

◉ថ្ងៃខែឆ្នាំសម្រាល:............./............./......................... ម៉ោងសម្រាល:.............................................

◉ទីកន្លែងសម្រាល:......................................................................................................

ដែលអាសយដ្ឋាន: សង្កាត់/ឃុំ.........................................ខណ្ឌ/ស្រុក/ក្រុង.........................................រាជធានី/ខេត្ត ..................................

◉ទឹកប្រាក់ទទួលចំនួន .......................................................................តាមរយៈ: ☐ អេស៊ីលីដា Acleda Bank លេខទូរស័ព្ទ:..................................

☐ វីង Wing. លេខគណនី:..................................

☐ វីង Wing. លេខទូរស័ព្ទ:..................................

❹ ឯកសារភ្ជាប់

☐-ប័ណ្ណសមាជិក ប.ស.ស

☐-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (សាមីជន)

ខ្ញុំសូមសន្យាថារាល់ព័ត៌មានដែលបានផ្តល់ខាងលើពិតជាត្រឹមត្រូវប្រាកដមែន។

ថ្ងៃ..................... ខែ....... ឆ្នាំ..... .......... ព.ស ២៥៦..

.................ថ្ងៃទី............ខែ..............ឆ្នាំ២០១...

**ស្នាមមេដៃ និងឈ្មោះសាមីជន**

**បានឃើញ និងបញ្ជាក់ថា**

ឈ្មោះ:..............................ពិតជាបានសម្រាលកូនចំនួន......នាក់

នៅ......................................................................................

..............................................................ពិតប្រាកដមែន។

ថ្ងៃ..................... ខែ........ ឆ្នាំ...... .......... ព.ស ២៥៦...

...........ថ្ងៃទី............ខែ.............. ឆ្នាំ២០១...

**ហត្ថលេខា និងឈ្មោះគ្រូពេទ្យ**

# បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)
# National Social Security Fund ( N S S F )

ធានាសន្តិសុខប្រាក់ចំណូល រួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ជីវភាពកម្មករនិយោជិត

**លេខទំនាក់ទំនងបន្ទាន់ 1286**
**24/7 ថ្ងៃ**

## កម្មករនិយោជិតក្នុងប្រព័ន្ធ





កម្មករនិយោជិត

សំដៅដល់ជនដែលធ្វើការទៀងទាត់ក្នុងមុខការអ្វីមួយ និងដែលមានលក្ខណៈជា **អចិន្ត្រៃយ៍** ហើយដែលទទួលបានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងហានិភ័យការងារតាមប្រព័ន្ធភាគទានដែលជាកាតព្វកិច្ចរបស់និយោជក។

## កម្មករនិយោជិតក្រៅប្រព័ន្ធ





សំដៅដល់កម្មករនិយោជិតដែលចុះកិច្ចសន្យាធ្វើការងារមួយដែលមានរយៈពេលមួយមិនលើសពី ៨ម៉ោងក្នុងមួយសប្តាហ៍ធ្វើការងារមួយពេលៗធ្វើឈប់ៗ ឬធ្វើការងារមួយរដូវៗហើយបានចុះបញ្ជីក្នុង ប.ស.ស។

## មូលនិធិសមធម៌សុខាភិបាល






សំដៅដល់យន្តការហិរញ្ញប្បទានផ្នែកគាំពារសុខភាពសង្គមដើម្បីផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋជាក្រុមគោលដៅមួយចំនួនទទួលបាន ឬប្រើប្រាស់សេវាថែទាំសុខភាពដោយឥតបង់ថ្លៃ នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈដែលរាជរដ្ឋាភិបាល ជាអ្នកទទួលបន្ទុកបង់ថ្លៃជំនួស។